ការសំភាសន៍របស់ លោកយាយ រៀម រ៉េត
កៈ អ្នកធ្វើការសំភាសន៍ដោយរូបខ្ញុំបាទ គីម ម៉េង ឧៈ អ្នកដែលត្រូវបានគេសំភាសន៍មានឈ្មោះលោកយាយ រៀម រ៉េត ៕
ប្រវត្តិសង្ខេបរបស់លោកយាយ រៀម រ៉េត
លោកយាយ រៀម រ៉េត គាត់មានអាយុ ៧០ ឆ្នាំ ក្នុងឆ្នាំ ២០១៩
លោកយាយ រៀម រ៉េត គាត់មានភេទ ស្រី
លោកយាយ រៀម រ៉េត មានទីលំនៅនាពេលបច្ចុប្បន្ន នៅភូមិមហាទេព សង្កាត់ចំការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង
កៈ
ចឹងជាដំបូងដំរាសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបើបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញលោកយាយដើម្បីចង់សួមសំភាសន៍លោកយាយពីជីវិប្រវត្តិរបស់លោកយាយខ្លះដែលលោកយាយបានរស់នៅក្នុងជំនាន់ប៉ុលពតថាតើលោកយាយបានរស់នៅក្នុងជំនាន់មានភាពលំបាកយ៉ាងមិចខ្លះឬក៏ស្រួលដែលរឺទេ
បានហើយចឹងប្រហែលជាខ្ញុំចង់សួមលោកយាយដើម្បីសំភាសន៍លោកយាយអំពីជីវិតរបស់លោកយាយបន្តិចបានដែលរឺទេលោកយាយ ???
ឧៈ បាសបាន។ ៕
កៈ បានហើយចឹងសំរាប់ថ្ងៃដែលខ្ញុំបានសំភាសន៍លោកយាយគឺជាថ្ងៃទី ២៤ ខែ ០៤ ឆ្នាំ ២០១៩
ហើយសំរាប់សំភាសន៍ដោយខ្ញុំបាទឈ្មោះ គីម ម៉េង
បានហើយចឹងសំរាប់លោកយាយថាតើលោកយាយមានឈ្មោះអ្វីដែលទៅលោកយាយ ???
ឧៈ បាសនិយាយទៅសំរាប់ឈ្មោះរបស់ខ្ញុំគឺ រៀម រ៉េត ហើយសំរាប់ឈ្មោះក្រៅគឺគេបានហៅថា រៀម សំបុក បាស ៕
កៈ បានហើយយ៉ាងមិនបានជាគេបានដាក់ឈ្មោះអោយលោកយាយយ៉ាងចឹងដែលទៅលោកយាយ ???
ឧៈ
បាសនិយាយទៅគឺឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងគឺគាត់បានដាក់ឈ្មោះទាំងអស់នឹងអោយមកខ្ញុំចឹងហាសហើយសំរាប់មិនដឹងដែលនោះទេហេហេហេ
ហើយសំរាប់ឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងគឺគាត់វេទនាតាំងពីខ្ញុំនឹងនៅតូចហើយសំរាប់ម្តាយរបស់ខ្ញុំនឹងគឺខ្ញុំមិនដែលបានស្គាល់មុខរបស់ម្តាយរបស់ខ្ញុំនោះទេ
ហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់មានប្រពន្ធចុងទៀតចឹង
គឺ៣នាក់បងប្អូនរបស់ខ្ញុំនឹងបានទៅរស់នៅខាង ខេត្ត កំពត ហាស
ហើយសំរាប់ម្តាយរបស់ខ្ញុំនឹងក៏គាត់បានស្លាប់នឹងនៅខាងខេត្ត កំពត
ដែលនឹងហាសបាសហើយដល់ពេលចឹងគឺឪពុករបស់ខ្ញុំនឹងគឺគាត់បានដាក់ឈ្មោះថ្មីអោយខ្ញុំពីព្រោះអីនឹងគឺគាត់បានឃើញខ្ញុំនឹងមានសាច់ហាសបាសគឺគាត់បានដាក់ឈ្មោះអោយខ្ញុំថា សំបុក។
ហាសតែសំរាប់ឈ្មោះនៅក្នុងបញ្ជីជាតិនឹងគឺមានឈ្មោះថា រៀម រ៉េត ចឹងទៅហាសបាស
ហើយសំរាប់ខ្ញុំមានបងប្អូននឹងចំនួន ៣ នាក់ហើយបងប្អូនរបស់ខ្ញុំនឹងគឺសុទ្ធតែស្រីទាំងអស់នឹងហាសបាស
ហើយសំរាប់បងទីមួយ គាត់មានឈ្មោះថា រៀម ព្រឿង ហើយសំរាប់បងទី២គាត់មានឈ្មោះថា រៀម ព្រឿង
ហើយសំរាប់គាត់បានស្លាប់តាំងពីនៅក្នុងជំនាន់សង្គមមកម្ល៉េសនឹងហាសបាស ៕
កៈ បានហើយចឹងសំរាប់បងរបស់លោកយាយគាត់បានស្លាប់ដោយសារតែអ្វីដែលទៅលោកយាយ ???
ឧៈ បាសនិយាយទៅនៅក្នុងជំនាន់នឹងគឺគាត់ប្រហែលជាកើតពិសនឹងហាស ហើយបានតែ ៧ថ្ងៃ
នឹងគឺគាត់បានស្លាប់បាត់ចឹងហាសបាស
ហើយសំរាប់ខ្ញុំ៣នាក់បងប្អូននឹងគឺរស់នៅនឹងគឺមិនដែលបានសុខនោះទេពីព្រោះអីនឹងគឺយើងបានហូបបាយជាមួយនឹងឪពុកមារបស់យើងនឹងគឺយើងហូបបាយមិនដែលបានឆ្អែតនោះទេបាស
និយាយទៅគឺយើងដើរតែស៊ីឈ្នួលគេរែតដីរែតសាច់អោយគេចឹងហាសបាស ៕
កៈ
បានហើយចឹងសំរាប់លោកយាយចង់សួរលោកយាយបន្តិចថាសំរាប់លោកតាហើយនឹងលោកយាយរបស់លោកយាយគាត់មានឈ្មោះអ្វីដែលទៅលោកយាយ ???
ឧៈ បាសនិយាយទៅសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា សួន ណារិន
ហើយសំរាប់លោកយាយរបស់ខ្ញុំនឹងគឺគាត់មិនដឹងជាឈ្មោះអ្វីនោះទេ
តែគ្រាន់តែដឹងថាគេបានហៅគាត់នឹងគឺថាយាយយួនៗចឹងហាសនឹងសំរាប់ខាងម្តាយរបស់ខ្ញុំនឹងហាសបាស
ហើយសំរាប់លោកតា នឹងគឺគាត់មានឈ្មោះថា តា សួន
ដែលគាត់ត្រូវជាប្តីរបស់លោកយាយយួននឹងហាសបាស ហើយនិយាយទៅគឺគាត់មានឈ្មោះថា តា សួន
តែសំរាប់ត្រកូលរបស់គាត់នឹងគឺមិនដឹងជាស្អីនោះទេគឺខ្ញុំមិនបានចាំនោះទេបាស
ហើយសំរាប់ខាងឪពុករបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា សយ រៀម បាស
និយាយទៅលោកតាគាត់មានឈ្មោះថា តា សយ ហើយលោកយាយ គាត់ក៏មានឈ្មោះ សយ
ដែលចឹងហាសបាសហើយសំរាប់លោកទាំង២នាក់គឺគាត់បានរស់នៅភូមិ កកុល
នឹងឯងនឹងហាសបាសនឹងសំរាប់ស្រុកកំណើតខាងឪពុកនឹងហាស
ហើយសំរាប់ស្រុកកំណើតខាងម្តាយវិញនៅខាង គុយ មែល ហើយសំរាប់អូនឯងមានស្គាល់ស្រុក គុយ មែល ដែលរឺទេ ៕
កៈ បានហើយចឹងសំរាប់ស្រុកនឹងនៅខាងខេត្ត ណាដែលទៅលោកយាយ ???
ឧៈ បាសនិយាទៅសំរាប់ គុយ មែល នឹងគឺនៅខាងស្រុក អង្គរបុរី
ហាសបាសហើយសំរាប់ស្រុកមួយនឹងនៅខាងខេត្ត បន្ទាយមានជ័យ ហាស
ហើយដល់ពេលចឹងទៅសំរាប់លោកគ្រូបង់បាប់ផ្តើមពីកន្លែងទៅកន្លែងណាគឺខ្ញុំនឹងនិយាយអោយស្តាប់ហាសបាសរីក៏និយាយត្រឹមនៅក្នុងជំនាន់ប៉ុលពត
រីក៏ត្រឹមកន្លែងណាបាសហើយប្រសិនជានិយាយនៅក្នុងជំនាន់ប៉ុលពតនឹងគឺរាវែងពេកទេដឹងលោកគ្រូ
ហើយនិយាទៅសំរាប់ប្រវត្តិរបស់ខ្ញុំនឹងប្រសិនជានិយាយ ១០ ថ្ងៃនឹងក៏មិនចប់ដែលចឹងហាសបាស
និយាយទៅគឺខ្ញុំវេទនាខ្លាំងណាស់គឺខ្ញុំមិនដែលបានសប្បាយនោះទេ
ហើយសំរាប់បងរបស់ខ្ញុំនឹងហើយនឹងម្តាយរបស់ខ្ញុំបានស្លាប់បាត់ទៅ
ដូចថាគេយោលគេក្រាប់គ្នាចឹងទៅហាសបាសនៅខាងខេត្ត កំពត
នឹងហើយសំរាប់លោកយាយរបស់ខ្ញុំនឹងគឺគេបាននៅខាង បាត់ទេស
ហាសបាសហើយសំរាប់ជំនាន់ពីដើមនឹងគឺគេបានរែខ្សែលោសទេហាស

ហើយសំរាប់បងរបស់ខ្ញុំនឹងគឺគាត់បាននិយាយថាគឺគាត់ធំជាងហើយគាត់បានដឹងរឿងទាំងអស់នឹង
ហើយសំរាប់ខ្ញុំមិនបានដឹងច្រើននោះទេពីព្រោះអីនឹងគឺខ្ញុំនៅតូចខ្លាំងណាស់ចាស
ហើយនៅពេលដែលវៃដោយខ្សែលោសនឹងហើយនៅខាងបាក់ទះហើយនឹងគឺគេបាននិយាយថា
ហើយសំរាប់កូនដែលមានឈ្មោះ រិន នឹងគឺគាត់បានស្លាប់បាត់ហើយចឹងសំរាប់ម្តាយនឹងគឺគាត់មានឈ្មោះថា
លោកយាយ ឃួន នឹងហាសចាស ហើយប្រសិនជាលីយប់អោយគាត់នឹងទៅទាំងយប់
ហើយប្រសិនជាលីពេលថ្ងៃអោយគាត់នឹងទៅទាំងពេលថ្ងៃនឹងតែម្តងនឹងហាសចាស
ហើយដល់ពេលចឹងខ្ញុំទាំងពានាក់នឹងគឺដើរសុំទានគេនឹងហាសចាស
ហើយនៅពេលដែលយើងសុំទានគេនឹងគឺដូចជាយើងនឹងនៅជាមួយនឹងគេនឹងហាស
ហើយនៅពេលដែលម្តាយរបស់ខ្ញុំនឹងបានស្លាប់បាត់អស់ទៅខ្មោចម្តាយរបស់ខ្ញុំនឹងគឺគាត់នៅមន្ទីពេទ្យ
ហើយសំរាប់ពួកខ្ញុំដែលបានរស់នៅជាមួយនឹងគេនឹងគឺគេបានអោយខ្ញុំនឹងដើរសុំទានគេចឹងហាសចាស
ហើយសំរាប់បងទី១របស់ខ្ញុំនឹងគឺគាត់កាន់ផ្ទៃ
ហើយសំរាប់បងទី២របស់ខ្ញុំនឹងគឺគាត់កាន់ប្អូនចឹងហាសចាស
ហើយនិយាយទៅគឺយើងវេទនាខ្លាំងណាស់សំរាប់បងប្អូនរបស់ខ្ញុំនឹងហាសចាស
ហើយសំរាប់យើងនៅពេលដែលយើងមានប្តីនឹងគឺយើងបានមករស់នៅខាងអណ្តូងប្រេងហាសចាស
ហើយសំរាប់ដំនាន់នឹងនៅក្នុងឆ្នាំ ១៩៧៥ នឹងគឺពួកប៉ុលពតនឹងគឺគេបានចូលមកនឹងហាសចាស
នៅក្នុងឆ្នាំ ១៩៧៥ នឹងគឺខ្ញុំមានបានកូនម្នាក់ហើយចឹងហាសចាស
ហើយដល់ពេលចឹងគឺខ្ញុំបានរស់មកថៃទៀតនឹងហាសនិយាយទៅគឺនៅជិតភ្នំសំពៅនឹងហាសចាសនិយាយទៅ
គឺគេបានដំលៀសយើងនឹងទៅនៅខាងអាងពារនឹងហាសចាសហើយសំរាប់ដំនាន់នឹងគឺអត់មានរទេះអ្វីនោះ
ទេចាស
ហើយនិយាយទៅប្រសិនជាយើងមានឆ្នាំងហើយនឹងមានចានចឹងគឺយើងមានរបស់សំរាប់ដាំបាយហូបចឹង
ទៅហាសចាស ហើយសំរាប់នៅក្នុងដំនាន់នឹងគឺគេបានបង្កើតជាក្រុមសំរាប់ពេលដំបូងឡើយនឹងហាសចាស
ហើយនៅពេលដែលគេបានចែកជាក្រុមហើយចឹងគឺគេបានចែកស្រូវនឹងនូវមួយក្រុមគ្រួសារបាន២ជាវចឹង
ហាសចាស
ហើយនៅពេលដែលយើងហូបអស់២ជាវនឹងហើយចឹងបានគេបានអោយយើងនឹងហូបរួមចឹងហាសចាស
ហើយសំរាប់ការហូបរួមនឹងគឺគេបានអោយយើងនឹងហូបជាមួយនឹងគ្នាចឹងហាសតែសំរាប់ការហូបអោយបាន
ឆ្អែតនឹងគឺមិនឆ្អែតនោះទេ
តែសំរាប់ពេលនឹងគឺយើងមិនបានហូបបបរនោះទេចាសនឹងគឺខ្ញុំនិយាយតាមត្រង់នឹងហាសចាស
ហើយសំរាប់នៅខាងរបស់ខ្ញុំនឹងគឺគេមិនមានបបរដែលរាយនោះទេហើយសំរាប់ការហូបបានឆ្អែតរីក៏មិនបា
នឆ្អែតនឹងគឺគេបានអោយយើងនឹងដឹងតែម្នាក់ចឹងហាស
ហើយសំរាប់ខ្ញុំមានកូនចៅច្រើនចឹងគឺយើងបានចែករំលែកចឹងទៅហាស
ពីព្រោះអីនឹងគឺគាត់ទាំងអស់ចាស់ៗហើយគឺគាត់ហូបបានច្រើនចឹងហាស
ហើយនៅពេលដែលប្អូនគេបានចូលមកនឹងគឺពួកយើងនឹងបានរត់ចូលទៅខាងរកា
ហើយនៅពេលដែលរត់ចេញពីខាងរកាហើយចឹងទៅច្រើនកន្លែងចឹងទៅគឺខ្ញុំបានរត់ទៅខាងដុំរុំវិញចឹងហាស
ចាស ហើយសំរាប់រត់ទៅដុំរុំនឹងគឺរត់កាត់គ្រាប់ហើយនឹងរត់កាត់ខ្មោចគឺទំរាំតែទៅដល់ចឹងហាស
ហើយនិយាយទៅគឺយើងទាំងអស់គ្នានឹងគឺវេទនាខ្លាំងណាស់ចាស
ហើយសំរាប់គេបានដឹកខាងពីដានពីអីចឹងទៅគឺសំរាប់ខ្ញុំគឺមិនបានទៅនឹងគេនោះទេចាសនិយាយទៅគឺយើ
ងមិនបានទៅជាមួយនឹងគេនោទេចាស
តែសំរាប់ខ្ញុំគ្រាន់តែប្រាប់ថានៅក្នុងដំនាន់នឹងគឺពិតជាសាហាវខ្លាំងណាស់ចាសនឹងគឺខ្ញុំគ្រាន់តែប្រាប់ប៉ុននឹ
ងចឹងហាសចាស
ហើយសំរាប់កូនរបស់ខ្ញុំម្នាក់នឹងគឺពួកវានឹងមិនបានអោយយើងនឹងរស់នៅជាមួយនឹងគ្នានោះទេ
គឺពួកវានឹងបានអោយកូនបស់ខ្ញុំនឹងបានទៅក្នុងព្រៃ ហើយកាប់ដើមឈើនឹងដើរប្រមូលដើមជាងខេត្ត
នឹងហាសចាស ៕
ក៖ បាទហើយចឹងសំរាប់កូនរបស់លោកយាយទាំងអស់គ្នាមានប៉ុន្មាននាក់ដែលទៅលោកយាយ ???
ខ៖ ចាសនិយាយទៅសំរាប់កូនរបស់ខ្ញុំទាំងអស់មានគ្នា ៥ នាក់
ហើយបានស្លាប់កូន១ម្នាក់ដែលគាត់ជាបងគេចឹងហាសចាសចឹងហើយគឺនៅសល់តែកូន ៤
នាក់នោះទេចាស ហើយសំរាប់កូនដែលគាត់បានមកអង្គុយមុននឹងចឹងហាស
ហើយសំរាប់កូនម្នាក់នឹងគឺវាទើបតែឆ្លងទន្លេរហាសចាស
ហើយនៅពេលដែលវានឹងហើមនឹងគឺវានឹងបានទៅពេទ្យធំ
ហើយទៅពេទ្យហើយចឹងគឺគេបានអោយវានឹងទៅពេទ្យឃុំ
ហើយសំរាប់ពេទ្យឃុំនឹងគឺគេបាននិយាយថាគឺវានឹងមានដំងឺលើសឈាមចឹងហាសចាស
ហើយដល់ពេលកំគេបានបញ្ជូនវានឹងទៅពេទ្យធំ ហើយនៅពេលដែលគេបានអោយទៅពេទ្យធំហើយចឹង
គឺគេចេះតែទុក្ខវាចឹងទៅគឺគេបានចាក់ថ្នាំ
ហើយទុក្ខវានឹងរហូតដល់ហូរឈាមគឺយើងអោយពេទ្យនឹងគឺអោយវះកូននឹងចឹងហាស
ហើយនៅពេលដែលយើងអោយគេវះក៏គេមិនវះ ហើយនៅពេលដែលវះហើយចឹងហើយបានកូន
ហើយសំរាប់ម្តាយរបស់គេនឹងគឺជិតបានដឹងខ្លួនហើយចឹងក៏គេបានយកម្តាយនឹងទៅវះម្តងទៀត
ហើយសំរាប់ការវះកាត់នឹងគឺវះកាត់គ្នានឹងអស់ចំនួន ២
ដងហើយវះកាត់នឹងវះដៃស្លួនហើយយកមកដាក់កន្ទាំង
ហើយដល់ពេលចឹងគឺគេបានដាក់ខ្សែអុកស៊ីស្សែនគ្នា
ហើយនៅពេលដែលចឹងគឺគេបាននិយាយថាគឺគេមិនបានដឹងខ្លួននោះទេចឹងហើយគឺគេបានអោយយើងនឹ
ងដឹកទៅផ្ទះរបស់យើងចឹងហាសចាស
ហើយនៅពេលដែលពេទ្យបាននិយាយចឹងហើយគឺខ្ញុំក៏បានសួរពេទ្យវិញថាប្រសិនជាខ្ញុំបានដឹកកូនរបស់ខ្ញុំនឹ
ងមកផ្ទះចឹងថាតើកូនរបស់ខ្ញុំវាអាចនឹងរស់ដែលរឺទែ
ហើយសំរាប់ពេលនឹងគឺពេទ្យរបស់គេនឹងបាននិយាយថាប្រសិនជាដកអុកស៊ីស្សែននឹងគឺដឹងតែស្លាប់ហើយចឹ
ងហាស ហើយប្រសិនជាទុកអុកស៊ីស្សែននឹងវាអាចនឹងរស់បានយូរចឹងហាសចាស
ហើយដល់ពេលចឹងគឺយើងក៏បានសំរេចចិត្តថាទុក្ខវាអោយបានរស់បានយូរចឹងហាស
ហើយដល់ពេលយូរចឹងទៅក៏កូនរបស់ខ្ញុំនឹងបានស្លាប់ចោលបាត់របស់ខ្ញុំចឹងទៅហាសចាសហើយនិយាយទៅ
គឺខ្ញុំនឹងកូនរបស់ខ្ញុំនឹងគឺមានភាពវេទនាខ្លាំងណាស់ចាស
ហើយដល់ពេលក្រោយមកកូនរបស់ខ្ញុំនឹងបានស្លាប់អស់ម្នាក់ទៀត
គឺវានឹងបានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍នឹងហាសចាស
ហើយសំរាប់ពេលនឹងគឺជាពេលបិណ្ឌមួយនឹងហើយនៅពេលដែលចប់ហើយចឹង
ហើយនិយាយទៅសំរាប់កូនរបស់ខ្ញុំទាំងអស់គ្នាមានចំនួន ៥ នាក់

ហើយពួកវានឹងបានទៅអស់ហើយចឹងហាស ហើយលូវនឹងគឺគេបានរស់នៅសល់តែ ៣ នាក់នោះទេគឺនៅសល់ប្រុស ១ ហើយនឹងស្រី ២ នាក់នោះទេសំរាប់ពេលនឹងចឹងហាសចាស
ហើយប្រសិនជាសរុបកូនរបស់ខ្ញុំទាំងអស់នឹងគឺ៥ នាក់ តែមានប្រុសនឹងចំនួន ៣ នាក់
ហើយនឹងស្រីនឹងចំនួន ២ នាក់ចឹងហាសចាស ។
ក៖
បានហើយចឹងចង់សួរលោកយាយបន្តិចថាសំរាប់ប្តីរបស់លោកយាយគាត់មានឈ្មោះអ្វីដែលទៅលោកយាយ ???
ខ៖ ចាសនិយាយទៅគឺសំរាប់ប្តីរបស់ខ្ញុំគឺគាត់មានឈ្មោះថា សៀម រៀម
តែសំរាប់ខ្ញុំហើយនឹងគាត់នឹងបានលេងលះគ្នានឹងយូរហើយចឹងហាសចាស
ហើយសំរាប់ការលេងលះគ្នានឹងគឺខ្ញុំបានលេងគ្នាតាំងពីកូនរបស់ខ្ញុំនឹងនៅតូចចឹងហាសហើយនិយយាទៅសំរាប់លេងលះគ្នានឹងគឺជាង ២០ ឆ្នាំទៅហើយហាសចាស
ហើយនិយាយទៅគឺប្រហែលជាប៉ុននឹងឯងចឹងហាសពីព្រោះអីនឹងគឺយូរហើយចឹងហាសប្រហែលជា ២០ ឆ្នាំមកហើយនឹងហាសចាស
ហើយសំរាប់នាក់ដែលបានរស់នៅនឹងក៏បានលេងលះប្តីរបស់វាដែលចឹងហាសហើយសំរាប់មួយនឹងគឺក៏ពួកវានឹងក៏មេមាយដែលចឹងហាសចាសគឺបានលេងលះប្តីរបស់វាដែលចឹងហាសចាស
ហើយសំរាប់កូនចៅរបស់ខ្ញុំនឹងគឺវានៅមួយទៀតដែលបានលេងលះគ្នាចឹងហាសចាស
ហើយនឹងគឺខ្ញុំបានចិញ្ចឹមចៅរបស់ខ្ញុំនឹងមួយទៀតដែលវានឹងបានបៅទឹកដោះគោរហូតមកនឹងហាសចាស
ហើយសំរាប់ខ្ញុំបានដើរស៊ីឈ្នួលគេ ហើយនឹងដកស្លូងគេចឹងហាស
ហើយើសំរាប់លូវនឹងគឺវាមិនហ៊ាននោះទេចាស ហើយសំរាប់ពេលខ្លះនឹងគឺខ្ញុំដើរស៊ីឈ្នួលគេគឺច្រើនកន្លែង
ហើយនឹងពេលខ្លះនឹងគឺខ្ញុំបានដើរទៅបេះត្រកួន
ហើយនឹងបេះស្លឹកខ្នឹងចឹងទៅហាសចាសដើម្បីបានលុយមកជួយចិញ្ចឹមចៅចឹងទៅហាសចាស
ហើយនិយាយទៅសំរាប់ចៅដំបូងនឹងគឺយើងអត់មានលទ្ធភាពដើម្បីទិញទឹកគោនោះទេ
ហើយដល់ពេលចឹងទៅគឺខ្ញុំបានដាក់ទឹកបបរនឹងគឺលាយជាមួយនឹងទឹកដោះគោ
ហើយនៅពេលដែលអត់មានទឹកដោះគោនឹងហើយគឺខ្ញុំទិញតែស្ពរសនឹងមកហើយនឹងបានដាក់ជាមួយនឹងទឹកពាងចឹងទៅហាសចាសហើយនៅពេលដែលដាក់ហើយចឹងគឺយើងបានស្ពរហើយនឹងជាមួយនឹងទឹកពាងហើយក៏ក្រឡកហើយអោយចៅរបស់ខ្ញុំនឹងបានបាវទៅហាសចាស
ហើយសំរាប់ចៅរបស់ខ្ញុំលូវនឹងគឺពួកវានឹងធំអស់ហើយចឹងហាស
ហើយសំរាប់លូវនឹងគឺពួកវានឹងពួកវានឹងបានទៅរៀនអស់ហើយចឹងហាសចាស ។
ក៖
បានហើយចឹងនៅពេលដែលអោយពួកគាត់បានបាវចឹងហាសថាតើពួកគាត់អត់មានអារម្មណ៍ហើមពោះហើយនឹងមានជំងឺណឺអ្វីនោះទេមែនដែររឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺអត់អីដែលចឹងហាសនិយាយទៅគឺបានសុខសប្បាយដែលចឹងហាស
ហើយសំរាប់ការណឺអីនឹងគឺយើងកំរលខ្លាំងណាស់ចាសនិយាយទៅគឺមិនអីដែលចឹងហាស
ហើយនិយាយទៅគឺអាចថាពួកចៅរបស់ខ្ញុំទាំងអស់នឹងគឺថាដូចជាសំណាងដែលចឹងហាសចាស
ហើយសំរាប់ឱពុករបស់វាដែលបានត្រោះថ្នាក់ចរាចរណ៍នឹងក៏មិនបានត្រោះថ្នាក់ខ្លាំងដែលចឹងហាសចាស
ហើយសំរាប់ការណឺអ្វីនឹងក៏មិនអីដែលចឹងហាស ហើយសំរាប់ការហូបថ្នាំនឹងក៏បានត្រាន់ដែលចឹងហាសចាស
ហើយនៅពេលដែលហូបថ្នាំចឹងគឺគាត់នឹងបានមកផ្ទះវិញចឹងហាសចាស
ហើយសំរាប់យើងនៅក្នុងជំនាន់នឹងគឺមានមកពីណា
ហើយប្រសិនជាយើងនៅផ្ទះចឹងនៅក្នុងជំនាន់នឹងគឺគេបាននិយាយថាយើងនឹងគឺជានាក់មានហើយចឹងហាសចាស ហើយសំរាប់ផ្ទះអ៊ីម្នាក់នេះចឹងហាស
ហើយសំរាប់រាល់ថ្ងៃនឹងគឺគាត់គ្មានលុយកាក់នោះទេគឺមានតែផ្ទះនោះទេចាស
ហើយនិយាយទៅគឺគាត់គ្មាននោះទេចាស ហើយសំរាប់កូនរបស់គាត់ម្នាក់នោះទេគឺជាកូនប្រសារចឹងហាស
ហើយសំរាប់កូនបង្កើតរបស់គាត់នឹងគឺត្រូវបានស្លាប់បាត់ហើយចឹងហាសចាស
ហើយសំរាប់កូនរបស់គាត់នឹងក៏ជានាក់ក្រដែលចឹងហាស ហើយបានទៅស៊ីឈ្នួលគេដែលចឹងហាស
ហើយអ្វីក៏ធ្វើដែលអោយតែបានលុយចឹងហាសចាស ហើយសំរាប់នឹងបានទៅធ្វើសណង់
ហើយនឹងបានបើកអាត្រាក់ ហើយនឹងគោយន្ត
និយាយទៅធ្វើអ្វីក៏បានដែលចឹងហាសអោយតែបានលុយយកមកដើម្បីចិញ្ចឹមម្តាយចឹងហាសចាសតែសំរាប់លូវនឹងកូនទាំងអស់នឹងគឺគេបានធំៗអស់ហើយចឹងហាស ។
ក៖
បានហើយចឹងចង់សួរលោកយាយបន្តិចទៀតថាសំរាប់លោកយាយនៅពីក្មេងថាតើលោកយាយបានរៀនរឺក៏បានសិក្សាដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺនៅក្នុងជំនាន់នឹងគឺពួកយើងនឹងក្រខ្លាំងណាស់
ហើយសំរាប់ខ្ញុំនឹងប្រាប់កូនអោយត្រង់ហើយសំរាប់ខ្ញុំបានរស់នៅជាមួយនឹងម្តាយចាស់ហាសនៅក្នុងជំនាន់នឹងហាសចាស ហើយនៅពេលដែលយើងក្រពេកចឹងគឺយើងបានទៅរស់នៅម្តងនៅ វត្តនេះទៅ
ហើយម្តងគឺយើងទៅរស់នៅវត្តកន្លែងនោះចឹងទៅហាស
ហើយនិយាយទៅយើងទាំងអស់គ្នានឹងគឺដើររស់នៅតែនៅក្នុងវត្តនោះទេចាស
ហើយសំរាប់នៅក្នុងជំនាន់ពីដើមនឹងគឺយើងដើររ៉ែងដីខ្សាច់នោះទេ ហើយយើងអាចរ៉ែងបានចឹងហាសចាស
ហើយនៅពេលដែលយើងបានយកបង្កឹមកហើយចឹងយកមកដាក់ដីខ្សាច់នឹងហើយចឹងគឺយើងបានមកលើគោក ហើយនៅពេលដែលបានយកមកដាក់លើកគោកហើយចឹងគឺយើងចុះទៅយកដីទៀតចឹងហាសចាស
ហើយសំរាប់ការយកដី នឹងគឺមួយគៅនឹងគឺវាមានកន្លះម៉ែត្រចឹងហាស ហើយសំរាប់២គៅនឹងគឺមានចំនួន១ ម៉ែត្រចឹងហាសចាស
ហើយដល់ពេលដែលសង្គ្រាមជិតចប់ហើយចឹងគឺយើងបានទៅរស់នៅអូស្រឡៅវិញម្តងចឹងទៅហាសចាសនិយាយទៅគឺនៅខាងព្រែកត្រោបនោះទេ
ហើយនៅពេលដែលយើងនឹងបានទៅរស់នៅកន្លែងនឹងហើយចឹងគឺយើងទើបតែចាប់ផ្តើមនឹងរៀនបាន ក ខ ហើយនឹងបានតួជើងបានខ្លះអីចឹងទៅ ហើយនៅពេលដែលខ្ញុំបានចេះហើយបានបន្តិចចឹងទៅ
ហើយចឹងសំរាប់យាយរបស់ខ្ញុំនឹងក៏គេបានអោយគាត់នឹងមករស់នៅខាងលើវិញចឹងហាស
ហើយដល់ពេលចឹងគឺយើងនឹងមិនបានរៀនសូត្រនោះទេចាស
ហើយដល់ពេលចឹងគឺខ្ញុំនឹងបានមានទំនង់កូនម្នាក់ទៀតចឹងហាស
ហើយសំរាប់កូននឹងគឺជាកូនបងគេចឹងហាសចាស
ហើយសំរាប់កូននឹងគឺគេបានធ្វើអោយយើងនឹងបានល្អចឹងហាស
ហើយសំរាប់ខ្ញុំនៅពេលដែលបានកើតវាហើយចឹងគឺខ្ញុំបានយកសៀវភៅមក

គឺជាសៀវភៅខាងកុមារដ្ឋានចឹងហាសចាស ហើយសំរាប់ប្អូនរបស់ខ្ញុំនឹងគឺជាប្អូនជីដូនមួយចឹងហាស
ហើយនៅពេលដែលយកវាមកហើយចឹងហើយមើលថានៅសំរាប់សៀវភៅនេះគឺជាសៀវភៅតួអក្សររឹក៍អ្វីនឹងក៍យើងនឹងបានគិតថា សំរាប់ដើង
ហើយនឹងអក្សរនឹងនៅពេលដែលយើងបានបូកចូលគ្នាហើយចឹងគឺយើងអាចអានបានសំរាប់មួយពាក្យៗចឹងហាសចាស ហើយដល់ពេលចឹងគឺខ្ញុំចេះតែខំប្រឹងរៀនៗចឹងទៅក៍ខ្ញុំនឹងបានចេះ
ហើយសំរាប់ដំនាន់នឹងគឺដូចថាខ្ញុំនឹងគឺជាមនុស្សនឹងដែលល្ងង់ពេកនឹងហាស
ហើយនៅពេលនឹងគឺគេបានយកខ្ញុំនឹងទៅក៍គេនឹងបានបញ្ជូនខ្ញុំនឹងទៅកន្លែងផ្សេងនឹងអស់រយៈពេលបាន ៣ ខែទាំងកូនរបស់ខ្ញុំទាំងអស់ចឹងហាសចាស
ហើយនៅពេលដែលយើងបាន៣ខែហើយចឹងគឺយើងបានត្រឡប់មកវិញចឹងហាសចាស
ហើយនៅពេលដែលត្រឡប់វិញនឹងគឺគេបានអោយយើងនឹងមួយសប្តាហ៍នឹងគឺគេបានអោយយើងនឹងទៅរៀនថ្ងៃសៅរ៍ចឹងហាស
ហើយសំរាប់ដំនាន់នឹងគឺគេបានអោយយើងនឹងរៀនតែប៉ុននឹងថ្ងៃនោះទេសំរាប់ដំនាន់នឹងហាសចាស
ហើយសំរាប់ខោអាវរបស់ខ្ញុំនៅពេលដែលទៅរៀនគឺមានខោអាវតែមួយសំរាប់នោះទេ
ហើយនៅពេលដែលខ្ញុំបានទៅគឺខ្ញុំមកពីរៀនវិញគឺខ្ញុំបានដោះអាវនឹងហើយយកទៅបោក
ហើយនៅពេលដែលបោកបួចហើយចឹងគឺខ្ញុំព្រឹកឡើងទៅរៀនពាក់វាវិញទៀតចឹងហាសចាស
ហើយសំរាប់ថ្ងៃអាទិត្យនឹងគឺគេបានធ្វើការប្តូរការងារចឹងហាសចាសហើយនៅពេលដែលចឹងគឺគេបានចេញពលកម្មរបស់គេចឹងហាសចាស
ហើយនិយាយទៅគឺគេបានធ្វើពលកម្មនឹងបានដាក់ថង់គេដែឡចឹងហាសចាស
ហើយសំរាប់ពេលនឹងគឺខ្ញុំបានបណ្តុះសណ្តែកនឹងលក់ហាស
ហើយនៅពេលដែលខ្ញុំបានលក់សណ្តែកនឹងគឺខ្ញុំបានដើររើសថង់នឹងសំរាប់យកមកចឹងហាសចាស
ហើយនៅពេលដែលនឹងខ្ញុំដើរសុំថង់នឹងគឺខ្ញុំបានប្រាប់គេខ្ញុំយកថង់ទាំងអស់នឹងអោយទៅបងប្អូនរបស់ខ្ញុំចឹងហាសចាស
ហើយប្រសិនជាយើងទិញគេនៅទីកន្លែងនោះចឹងគឺយើងត្រូវចំណាយអស់១០កាក់ទៅ១៥កាក់ចឹងហាសចាស
ហើយសំរាប់ពេលនឹងគឺយើងបានកសូរហូតដល់បានកូនរបស់យើងបានមានអ្វីសំរាប់ហូបចឹងហាសចាស ៕
ក៖ បានហើយចឹងបាននិយាយថាសំរាប់លោកយាយបានរៀនបានខ្លះដែលមែនដែលរឺទេលោកយាយ ???
ខ៖ បាសនិយាយទៅគឺខ្ញុំបានរៀនបានខ្លះចឹងហាសចាស
តែគ្រាន់តែថានៅពេលដែលខ្ញុំបានរៀននឹងគឺខ្ញុំអត់មានសញ្ញាប័ត្រចឹងហាសចាស
ហើយនៅពេលដែលយួនគេបានចូលមកចឹងគឺយួនគេបានផ្លោងគ្រាប់មកចឹងគឺគេក៍បានយកសៀវភៅរបស់ខ្ញុំបាត់ទៅចឹងហាសចាស
ហើយសំរាប់ពីដើមនឹងគឺខ្ញុំអាចសរសេរអក្សរបានហើយនឹងមើលអក្សរបានចឹងហាស
ហើយសំរាប់មកកន្លះពេលលូវនឹងគឺខ្ញុំបានភ្លេចអស់បាត់ហើយចឹងហាសចាស
ហើយនិយាយទៅគឺខ្ញុំមានអាយុចាស់ហើយដែលចឹងហាស ហើយសំរាប់ខ្ញុំមានឆ្នាំ រក
ហាសហើយប្រសិនជាគិតអាយុមកនឹងគឺខ្ញុំមានអាយុ ៦៧ ឆ្នាំហើយចឹងហាស
ហើយសំរាប់យើងនៅពេលដែលព្រឹកឡើងនឹងគឺយើងបានដើរឡើងបេះស្លឹកអំពិលអីចឹងទៅហាសចាស
ហើយយើងទៅដកប្រលិតហើយនឹងទៅបេះក្រកួលអីចឹងទៅហាសចាស ៕
ក៖
បានហើយចឹងសំរាប់លោកយាយថាតើលោកយាយបានដើរទៅបេះនឹងទៅដល់ទីកន្លែងណាហើយនឹងទៅដើរទៅរៀននឹងដល់ទីកន្លែងណាដែលទៅលោកយាយ ???
ខ៖ បាសនិយាយទៅនៅក្នុងដំនាន់នឹងគឺយើងបានដើរបេះនឹងដល់ចំការដូងនឹងចឹងហាសចាស
ហើយនិយាយទៅគឺយើងបានដើរតាមក្រោយស្រែៗរបស់គេចឹងទៅហាសចាស
ហើយនៅពេលដែលយើងបានបេះហើយចឹងគឺយើងបានទុក្ខវាអោយបានមួយសន្ទុះចឹងទៅគឺគេបានមកយករបស់ទាំងអស់នឹងចឹងហាសចាស
ហើយនៅពេលដែលយើងបានរបស់ទាំងអស់នឹងហើយចឹងគឺយើងយករបស់ទាំងអស់នឹងយកមកដុសអោយវាបានស្អាតហើយនឹងយកទុក្ខអោយគេចឹងទៅហាសចាស
ហើយសំរាប់លូវនឹងគឺគ្មាននោះទេគឺមានតែស្លឹកខ្ចីងហើយនឹងស្លឹកត្រួយអំពិលនោះទេនៅពេលដែលធ្លាក់ភ្លៀរមកម្តងនឹងហាសចាស ហើយនិយាយទៅគឺយើងអាចដើរបេះបោចបានចឹងហាស
ហើយនិយាយទៅសំរាប់ប្រវត្តិរបស់ខ្ញុំនឹងគឺមិនដែលបានមានភាពសប្បាយនោះទេ
ហើយសំរាប់ផ្ទះមួយនេះនឹងគឺដូចថាយើងចេះតែសន្សំម្តងតិចៗចឹងទៅហាសចាស
ហើយមាននាក់ដែលជួយមកពីនេះមកពីនោះខ្លះចឹងទៅហាស
ហើយសំរាប់ខ្ញុំបានមកនេះគឺខ្ញុំបានមកដោយបាតដៃទទេនោះទេនៅពេលដែលខ្ញុំមកដល់កន្លែងនឹងចឹងហាសចាស ៕
ក៖
បានហើយចឹងចង់សួរលោកយាយបន្តិចពីខ្សែជីវិតរបស់លោកយាយសំរាប់លោកយាយគឺលោកយាយមានកូននឹងចំនួន ៥ នាក់នឹង
ហើយសំរាប់ការចិញ្ចឹមបីបាច់តាំងពីតូចរហូតដល់ពួកគាត់ទាំងអស់គ្នាធំៗរៀងៗខ្លួនចឹងថាតើលោកយាយមានការជួបបញ្ហាលំបាកអ្វីខ្លះដែលទៅលោកយាយ ហើយនឹងត្រូវការចំណាយប៉ុន្មានដែលទៅ
ហើយចឹងសំរាប់លោកយាយមានការលំបាកអ្វីខ្លះដែលទៅលោកយាយអាចប្រាប់បន្តិចបានដែលរឺទេលោកយាយ ???
ខ៖
បាសនិយាយទៅសំរាប់នៅក្នុងរឿងនេះនឹងនៅក្នុងការចិញ្ចឹមបីបាច់កូននឹងគឺយើងមានភាពលំបាកហើយចឹងសំរាប់កូន១កូន២នៅក្នុងដំនាន់ប៉ុលពតនឹងសំរាប់ កូនទី៣កូនទី៤កូនទី៥
គឺខ្ញុំបានកើតពួកវានឹងនៅក្នុងដុំរុំចឹងហាសចាស
ហើយដល់ពេលចឹងសំរាប់ការចិញ្ចឹមកូននឹងគឺយើងមានភាពលំបាក
ហើយសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់មានប្រពន្ធចុងទៀតចឹងហាសចាស
ហើយនៅពេលដែលគេមានប្រពន្ធចុងចឹងគឺខ្ញុំនឹងបាននៅគ្រប់គ្រងកូនទាំងអស់ចឹងហាសចាស
ហើយសំរាប់ដំនាន់ពីដើមនឹងគឺយើងរត់ពន្ធហាស
ហើយនៅពេលដែលរត់ពន្ធបានតិចៗចឹងទៅគឺយើងបានយកមកបានចិញ្ចឹមកូនអោយបានធំៗ
ហើយនៅពេលដែលពួកវាបានធំហើយចឹងគឺអោយពួកវានឹងបានចូលរៀនទៀតចឹងហាសចាស
ហើយនៅពេលដែលយើងបានរស់នៅទីកន្លែងនឹងគឺកូនរបស់យើងនឹងបានចូលរៀននឹងបានខ្លះ
ហើយសំរាប់កូនមួយទៀតនឹងគឺគាត់បានចូលបួស ហើយសំរាប់បានបួសកូនរបស់ខ្ញុំបាន ២
នាក់ដែលចឹងហាស គឺបួសកូនទី១ ហើយនឹងបួសកូនទី២

ចាសហើយនៅពេលដែលបានបួសហើយចឹងគឺដូចថាគឺយើងមានភាពពិបាកខ្លាំងណាស់
ហើយសំរាប់ការបួសនឹងគឺរួមមានទាំងកូនប្រសាកូនទាំងអស់គ្នាចឹងហាសចាសនិយាយទៅគឺយើងបាននាំគ្នានឹងទៅដីកក្តាម ហើយនៅពេលដែលទៅដីកក្តាមនឹងគឺយើងបានច្រើនខ្លាំងណាស់
ហើយនៅពេលដែលបានច្រើនហើយចឹងគឺយើងបានយកមកគឺយើងយកគឺង្គង់នឹងយកមកត្រាំហើយយកទៅលក់នៅខាងស្អែកទៀតចឹងហាសចាស
ហើយនៅពេលដែលចាប់បានគឺយើងអាកវានឹងហើយទុកវាហើយយកវានឹងទៅលក់ចឹងទៅហាសចាស ៕
ក៖ បាទហើយចឹងសំរាប់លោកយាយបានដើរទៅមែនដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺអត់នោះទេនៅពេលនឹងគឺយើងបានជួលម៉ូតូ
ហើយនឹងកង់ដើមដិះទៅផ្សារនឹងយករបស់ទាំងអស់នឹងទៅលក់ចឹងទៅហាស
ហើយសំរាប់ខ្ញុំនឹងគឺខ្ញុំមិនបានទៅលក់នោះទេ
គឺខ្ញុំបានអោយកូនរបស់ខ្ញុំនឹងគឺពួកវានឹងជានាក់លក់វិញចឹងហាសចាស
ហើយសំរាប់កូនរបស់ខ្ញុំម្នាក់នឹងគឺវាបានធ្វើឌុសចឹងហាស ហើយសំរាប់ខ្ញុំក៏សូមផ្តាំទៅកាន់កូនៗ
ហើយនឹងក្លួយទាំងអស់ ហើយនឹងចៅៗទាំងអស់ សូមអោយគេចអោយឆ្ងាយពីគ្រឿងញៀនចឹងហាសចាស
ហើយជាពិសេសនឹងគឺធីកស្រា
ហើយនឹងកុំអោយធ្វើអោយឪពុកហើយនឹងម្តាយរបស់យើងនឹងពួកគាត់នឹងបានខូចចិត្តចឹងហាសចាសពីព្រោះអីនឹងសំរាប់ឪពុកហើយនឹងម្តាយរបស់យើងនឹងពួកគាត់ទាំង២នាក់បានខំប្រឹងចិញ្ចឹមយើងនឹងតាំងពីតូចមកម្លេះចឹងហាសចាស ហើយក៏មិនហ៊ានអោយស្រមោចនឹងបានមកខាំយើងដែលចឹងហាស
ហើយនៅពេលដែលកូនៗធំហើយគឺគេបានធ្វើអាក្រក់ទៀតចឹងហាស
ហើយមានប៉ូលីសនឹងបានចាប់ហើយនឹងវែពួកកូននៅចំពោះមុខឪពុកហើយនឹងម្តាយចឹងគឺយើងទាំងអស់គ្នានឹងមានអារម្មណ៍ពិបាកចិត្តខ្លាំងណាស់ចាស ហើយចឹងសូមអោយកូនៗ
ហើយនឹងចៅៗទាំងអស់នឹងដើរចេញពីគ្រឿងញៀនកុំអោយសង្គមនឹងបានស្អប់ខ្ពើមយើង
ហើយសូមអោយក្លួយហើយនឹងកូនៗទាំងអស់នឹងបានធ្វើជាកូនល្អហើយនឹងចៅៗល្អនៅក្នុងសង្គមបានបានហើយចឹងប៉ុននឹងបានហើយចឹងចាស ៕
ក៖
បាទអរគុណច្រើនលោកយាយចង់សួរលោកយាយបន្តិចថានៅក្នុងជំនាន់ប៉ុលពតនឹងថាតើគេបានអោយលោកយាយនឹងបានធ្វើការងារអ្វីខ្លះដែលទៅលោកយាយហើយចង់ចូលពីសាច់រឿងរបស់លោកយាយនៅក្នុងជំនាន់ប៉ុលពតវិញម្តងចឹងហាសចាសលោកយាយ ???
ខ៖ ចាសនិយាយទៅនៅក្នុងជំនាន់ប៉ុលពតនឹងគឺគេបានអោយខ្ញុំនឹងបានទៅរែកដី
ហើយនឹងបានរែកហើយនឹងលើកអាងពារប្រឡាយអីទាំងអស់នឹងចឹងហាសចាស
ហើយសំរាប់នៅក្នុងមនុស្សម្នាក់នឹងគឺគេបានអោយយើងនឹងរែកដីនឹង៣ម៉ែត្រគិប នឹងហាសចាស ៕
ក៖ បាទហើយចឹងសំរាបជំរៅ ៣ ម៉ែត្រនឹងប៉ុនណាដែលទៅលោកយាយ ???
ខ៖ ចាសនិយាយទៅសំរាប់ ៣ម៉ែត្រ នឹងគឺវាមានន័យថា ៣ម៉ែត្រ ៤ ជ្រុងចឹងហាសចាស
ហើយសំរាប់របស់មួយនេះគឺវាមានចំនួន ២ម៉ែត្រទៅហើយចឹងហាស
ហើយសំរាប់បង្គីរបស់គេនឹងគឺយើងបានដាក់អាបង្គីដែលធំៗគឺគេបានឈ្មោះរបស់វាថានាងខ្ចាំមហើយណាកូន ហើយដូចថានៅក្នុងមួយក្រុមនឹងយើងបានយកគ្នាបាន ៣ ទៅ ៤ នាក់ហើយចឹងហាស
ហើយយើងបានវាស់ហើយចឹងទៅ គឺយើងទាំងអស់គ្នានឹងបានដាក់ទើសសំរាប់កាប់ចឹងទៅហាស
ហើយនៅពេលដែលយើងបានកាប់ហើយចឹងទៅគឺយើងបានកាយដាក់ៗចឹងហាស
ហើយសំរាប់ការងារមួយនឹងគឺយើងមិនអាចដាក់ពេលទំនេររបស់យើងនឹងបានមកអង្គុយលេងនោះទេ
និយាយទៅគឺយើងធ្វើការងារនឹងគឺយើងរត់ធ្វើតែម្តងចឹងទៅហាសចាស
ហើយសំរាប់ការឡើងនឹងក៏យើងនឹងរត់ ហើយសំរាប់ការចុះមកវិញនឹងគឺយើងក៏បានរត់ដែលចឹងហាស
ហើយធ្វើយ៉ាងមិចនៅក្នុងមួយម្នាក់នឹងគឺយើងត្រូវធ្វើការងារទាំងអស់នឹងអោយបាន ៣
ម៉ែត្រអោយគេចឹងហាសចាស ហើយនិយាយទៅគឺយើងឡើងទៅលើទំនប់របស់យើងចឹងហាសចាស
ហើយនិយាទៅគឺយើងឡើងនៅក្នុងម្នាក់នឹងគឺយើងធ្វើយ៉ាងមិចធ្វើអោយបាន ៣
ម៉ែត្រគិបអោយគេចឹងហាសចាស
ហើយសំរាប់នាក់ដែលគេមិនបានប្លូរនឹងគឺគេនឹងយកយើងនឹងទៅកសាងចឹងហាស
ហើយប្រសិនជាយើងជានាក់ដែលប្លូរចឹងគឺគេមិនបានកសាងយើងនោះទេ
ហើយសំរាប់យើងធ្វើយ៉ាងមិចអោយស្អាតចឹងហាសគឺយើងយកនាក់ដែលធ្វើការងារនឹងចាស់ៗដូចគ្នាហើយគាត់ជានាក់ដែលធ្វើស្រែចឹងហាស ហើយសំរាប់ពួកគាត់នឹងគឺធ្វើការងារនឹងគឺប្រឹងខ្លាំងណាស់ចាស
ហើយសំរាប់នាក់ខ្លះនឹងគឺគេបានចាប់ចំដៃសូរគ្នាប៉ះចំនាក់ដែរគាត់បានរស់នៅផ្សារចឹងទៅ
ហើយគ្នាមិនចេះធ្វើ ហើយសំរាប់ខ្ញុំអត់នោះទេគឺខ្ញុំចូលចិត្តនាក់ដែលគាត់មិនសូវប៊ិនចឹងហាសចាស
ហើយដល់ពេលចឹងគឺខ្ញុំខំប្រឹងយោងគ្នាដើម្បីធ្វើយ៉ាងមិចកុំអោយគេនឹងយកគាត់ទាំងអស់នឹងយកទៅសំលាប់ចោលចឹងហាសចាស
ហើយនិយាយទៅគឺគេនឹងយកយើងនឹងទៅសំលាប់ចោលចឹងហាសប្រសិនជាយើងនឹងធ្វើការងារទាំងអស់នឹងមិនរួចចឹងហាសចាស
ចឹងហើយគឺខ្ញុំអត់នោះទេទោះបីជាខ្ញុំធ្វើការងារច្រើនក៏ដោយក៏ខ្ញុំនឹងត្រូវតែធ្វើកុំអោយគេយកមនុស្សទាំងអស់នឹងសំលាប់ចោលចឹងហាសចាស
ហើយសំរាប់ខ្ញុំបានជួយគេនឹងគឺច្រើនខ្លាំងណាស់សំរាប់ការងាររបស់គេដែលមិនអាចនឹងធ្វើបានចឹងហាចាស
ហើយនៅពេលដែលយើងបានធ្វើការងាររបស់យើងហើយចឹងគឺយើងបានដើរមកវិញនឹងគឺយើងបានបេះស្វាយហើយនឹងត្នេនហើយនឹងបុកចឹងទៅ
ហើយសំរាប់មួយនឹងគឺគេមិនទាន់បានចូលជាសហការណ៍ខ្លាំងរបស់គេនឹងគឺសំរាប់មួយនឹងគឺគ្រាន់តែមធ្យមនោះទេ
ហើយនៅពេលដែលនៅខាងសហរកណ៍គេខ្លាំងនឹងគឺខាងនារីរបស់គេនឹងបានជិតចូលមកដល់ចឹងហាសចាស ហើយសំរាប់មួយនឹងគឺបានខ្លាំងចឹងហាស ហើយសំរាប់មួយនឹងគឺគេបានបុកហើយនឹងកិនគឺគេបានធ្វើការងារនឹងគឺខ្លាំងណាស់ ហើយគេបានធ្វើការងារនឹងទាំងយប់ទាំងថ្ងៃចឹងហាស
ហើយនៅពេលដែលដកហើយនឹងគឺសួងទៀតចឹងហាសចាស ហើយសំរាប់ការងារនឹងគឺម៉ោងនឹង ១០ ទៅ ម៉ោង ១១ ហាសក្លួយ ហើយសំរាប់ពេលនឹងគឺសំបូរទៅល្ងើងហាស
ហើយសំរាប់នៅខាងអាងប៉ុលពតនឹងគឺសំបូរខ្លាំងណាស់ចាស
ហើយសំរាប់នាក់ខ្លះនឹងគឺគេនឹងចេះតែដេរខោរបស់គេធ្វើយ៉ាងមិចអោយជិតចឹងហាសចាស
ហើយសំរាប់អាវដៃវែងរបស់គេនឹងគឺគេមិនមានដៃប្រហោងចឹង
ហើយចឹងគឺយើងបានដេរវានឹងអោយវានឹងបានជិតជាងចឹងទៅហាសចាស

ហើយនៅពេលដែលយើងបានដេរអាវរបស់យើងបានជិតហើយចឹងគឺយើងចេះតែលូតដកៗចឹងទៅហាស
ហើយសំរាប់សត្វពស់នឹងក៏យើងមានច្រើនដែលចឹងហាសចាសនិយាយទៅនៅក្តងជំនាន់នឹងគឺសំបូរខ្លាំងណាស់នៅខាងអាវព្រៃនឹងហាសចាស
ហើយសំរាប់ឈ្លើងនឹងគឺយើងគ្រាន់តែគូរមកនឹងគឺពួកអាឈ្លើងនឹងវាបាននាំគ្នាមកហើយចាស
ហើយសំរាប់ឈ្លើងនឹងគឺមិនជម្ងឺគានោះទេកូនអើយ ហើយដល់ពេល
ដែលគេធ្វើមិនបានចឹងគឺយើងជួយគ្នាចឹងទៅហាសចាសហើយយើងចេះតែជួយគ្នាចឹងទៅហាស
ហើយសំរាប់គេបានយកមនុស្សនឹងទៅសំលាប់អស់២គ្រួសារនឹងគឺខ្ញុំមានអារម្មណ៍ថាស្តាយខ្លាំងណាស់ចាស
ហើយសំរាប់គាត់នឹងគឺជាជនជាតិវៀតណាមចឹងហាស
ហើយសំរាប់គេបានយកគាត់នឹងទៅសំលាប់ចោលចឹងហាសគឺស្តាយខ្លាំងណាស់ចាស
ហើយសំរាប់គាត់នឹងគឺគេបានប្តឹជាវ៉ាងចឹងហាស
ហើយនៅពេលដែលគាត់បានប្តឹជាវ៉ាងចឹងគឺគេបានយកគាត់នឹងទៅសំលាប់ចោលចឹងហាសចាស
ហើយសំរាប់គាត់បានស្រែថាសំរាប់គាត់បានធ្វើអ្វីខុសៗចឹងហាសចាស
ហើយដល់ពេលចឹងគឺគេបានយកគាត់ទៅចឹងហាសចាស
ហើយសំរាប់ពេលនឹងគឺគេបាននិយាយថាយើងនឹងមិនចាំបាច់យកអ្វីមកជាមួយនោះទេចាស
ហើយដល់ពេលចឹងគឺគាត់បានសុំថាចាំខ្ញុំនឹងទៅយកកន្សែងសិនចឹងហាស
ហើយដល់ពេលចឹងគឺគេបាននិយាយថាមិនចាំបាច់នោះទេចាស
ហើយដល់ពេលចឹងគឺគេបានប្រាប់គាត់ទៀតថាមិនចាំបាច់យកនោះទេ
ហើយយើងគ្រាន់តែទៅរៀនសូត្រនឹងតែមួយភ្លេចតែប៉ុននឹងចឹងហាសចាស
ហើយនៅពេលដែលយកមកនឹងគឺគេបានយកគាត់នឹងទៅវៃចោលហើយនឹងបានកប់នៅកន្លែងដែលគេយកគាត់ទៅចឹងហាសចាស ហើយសំរាប់មួយគ្រួសារទៀតនឹងគឺគេជាជនជាតិចិនសុទ្ធហាសចាស
ហើយសំរាប់ម្តាយរបស់គេនឹងគឺមានអាយុវែងណាស់
ហើយសំរាប់កូននឹងគឺមានទំនង់នឹងគឺធ្លាស់ខ្លាំងណាស់ចាស
ហើយនៅពេលដែលគេបានមកយកមកនឹងគឺពួកវានឹងបានយកកូននឹងបោះតែម្តង
ហើយនៅពេលដែលបោះហើយចឹងគឺពួកវានឹងបានយកកាំបិតដំពុះទង់នឹងហាសយកមកចាក់ក្មេងនឹងតែម្តងនឹងហាសចាស ហើយសំរាប់ក្មួយឯងមានបានស្គាល់កាំបិតដំពុះទង់នឹងដែលរឺទេ
នឹងហើយនៅពេលដែលពួកវានឹងបានយកកាំបិទនឹងនៅពេលបោះក្មេងហើយចឹងគឺក្មេងបានចុះមកវិញនឹងបានជាប់នឹងកាំបិតនឹងចឹងហាសចាស ហើយដល់ពេលចឹងគឺគេបានវៃម្តាយដែលចាស់ៗនឹងហាសចាស
នៅពេលដែលពួកវាវៃចឹងគឺថាម្តាយអាក្មេងម្នាក់នឹងគឺគាត់បានរត់
ចាសនិយាយទៅនៅពេលដែលគេបានចាប់ផ្តើមវៃយើងនឹងគឺគេបានដាក់ខ្សែក្រៀមហើយចឹងហាសចាស
ហើយនៅពេលដែលរត់ៗហើយចឹង នៅពេលដែលគេបានចាប់បានហើយចឹងគឺគេបានវៃ
ហើយនៅពេលដែលវៃហើយចឹងគឺគេបានបាញ់សំលាប់ចោល
ហើយនៅពេលដែលសំលាប់ចោលហើយចឹងគឺពួកវានឹងបានអូសបញ្ជៀស
និយាយទៅគឺដូចជាអូសស្រូវចឹងហាស
គឺពួកវានឹងបានអូសជើងរបស់មនុស្សនឹងបានមកមុនចឹងហាសចាស
ហើយនៅពេលដែលគេបានអូសបញ្ជៀសចឹងគឺដៃរបស់គេនឹងបានលាប្រឡាយដូចជាអូសស្រូវចឹងទៅហាស
ហើយសំរាប់គាត់នឹងក៏បានស្លាប់បាត់បង់ជីវិតតែម្តងចឹងទៅហាស
ហើយសំរាប់គ្រួសារបស់គាត់នឹងបានស្លាប់បាត់
ហើយសំរាប់ខ្ញុំនឹងមានអារម្មណ៍ថាស្តាយខ្លាំងណាស់សំរាប់គ្រួសារមួយនឹងចឹងហាសចាស ។
ក៖
បានហើយចឹងសំរាប់គាត់បានធ្វើអ្វីខុសដែលទៅលោកយាយបានជាគេបានយកគាត់នឹងទៅសំលាប់ចោលយ៉ាងចឹងដែលទៅលោកយាយ ???
ខ៖
ចាសនិយាយទៅគឺខ្ញុំមិនបានដឹងដែលចឹងហាសចាសតែសំរាប់គាត់នឹងគឺជាថៅកែរោងម៉ាស៊ីនចឹងហាសចាស ហើយសំរាប់គាត់នឹងគឺជាថៅកែភ្នំសំពៅនឹងប្រហែលជាគាត់នឹងបានលាក់មាស ចឹងហាសចាស
ចាសនិយាយទៅគឺគាត់បានលាក់មាសនឹងហើយ
ពីព្រោះអីនឹងគឺគេបានឆែតមើលទៅគឺគេបានឃើញថាមានក្រឡរតាំងឆាយនៅពីក្រោមនឹងគឺគាត់បានលាក់មាស ហើយសំរាប់នៅពីខាងលើនឹងគឺគាត់បានដាក់ប្រហុកចឹងហាសចាស
ហើយសំរាប់គាត់នឹងបានដាក់ចឹង២ ទៅ ៣ ក្រឡរចឹងហាស ហើយនិយាយទៅគឺសុទ្ធមាសចឹងហាស
ហើយសំរាប់ចៃគឺគេបានថាគាត់នឹងគឺជាជនជាតិយួនចឹងហាស
ហើយនៅពេលដែលប្រាប់ចឹងហើយក៏គេបានសំលាប់គាត់នឹងចោលមួយពូជតែម្តងនឹងហាសចាស
ហើយសំរាប់ការសំលាប់កូនៗនឹងគឺនៅខាងអាងពារនឹងដែលនៅជាប់មាត់អាងនឹងតែម្តងចឹងហាសចាស
ហើយនៅពេលដែលសំលាប់គាត់នឹងបានប៉ុន្មានថ្ងៃនឹងគឺពួកនារគីនឹងគឺគេបានចូលមកចឹងហាសចាស
ហូរនឹងហើយគឺពួកនារគីនឹងបានសំលាប់បានប៉ុន្មានថ្ងៃនឹងគឺពួកយួននឹងគឺគេបានចូលមកចឹងហាសចាស
ហើយសំរាប់កុំអីនឹងក៏ខ្ញុំនឹងបានស្លាប់ដែលពីព្រោះអីនឹងគឺគេបានកៀលយើងគឺគេបានអោយយើងនឹងទៅភ្នំបែកចានចឹងហាស
ហើយនៅពេលដែលចេញពីនឹងហើយចឹងទៅគឺយើងមិនបានចុះទៅណាបាននោះទេពីព្រោះអីនឹងបងប្អូនហើយនឹងឪពុកហើយនឹងម្តាយរបស់យើងពួកគាត់ចាស់ៗអស់ហើយចឹងទៅហាសចាសគឺគាត់បានស្រែអោយយើងនឹងថាកុំទៅៗចឹងហាស ហើយដល់ពេលចឹងទៅគឺយើងមិនបានទៅនោះទេ
ហើយដល់ពេលគឺយើងបានបកមកក្រោយចឹងទៅក៏
គឺយើងនឹងយកមកហើយនឹងបាននៅខាងនឹងចឹងទៅហាសចាសហើយដល់ពេលក៏យើងនឹងបានរួចផុតតែម្តងចឹងទៅហាសចាស ។
ក៖
បានហើយចឹងនៅពេលដែលលោកយាយបានរត់ហើយចឹងហើយបានជួបជាមួយនឹងកងទព័វៀតណាមនឹងថាតើវៀតណាមគេមិនបានធ្វើបាបយើងនោះទេមែនដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺគេមិនបានធ្វើបាបយើងនោះទេចាស
និយាយទៅគឺបានវៀតណាមនឹងគឺគេបានហៅយើងនឹងអោយចូលមកទៀតនឹងហាស
តែសំរាប់យើងនឹងគឺមិនហ៊ាននឹងចូលទៅនោះទេសំរាប់ពេលដំបូងចឹងហាសចាស ។
ក៖ បានហើយចឹងនៅពេលដែលឃើញទាហ៊ានវៀតណាមចឹងហើយចឹងសំរាប់ទាហ៊ានប៉ុលពត
ហើយនឹងទាហ៊ានខ្មែរក្រហមនឹងពួកវានឹងបានរត់ទៅទីកន្លែងណាដែលទៅលោកយាយ ???
ខ៖ ចាសនិយាយទៅគឺពួកវានឹងបានរត់អស់ហើយចឹងហាសចាស
ហើយសំរាប់ពួកប៉ុលពតនឹងគឺពួកវានឹងបានមូលជើងខោមួយជំហៀង

ហើយនឹងដៃអាវរបស់ពួកវានឹងមួយចំហៀងចឹងហាសចាស
ហើយសំរាប់ពួកវានឹងបានលីកាំភ្លើងនឹងទៅខាងលិចអស់ហើយចឹងហាសចាស
ហើយសំរាប់យើងនៅពេលដែលយើងរត់មិនទាន់ចឹងទៅគឺយើងក៏បានស្លាប់ចឹងទៅ
ហើយសំរាប់នាក់ខ្លះនឹងគឺដោះខោអាវហើយគេក៏បានដើរចូលមកចឹងទៅហាស
ហើយសំរាប់យើងមានបានដឹងថានាក់ប៉ុលពតរឺក៏មិនប៉ុលពតចឹងហាសចាស
ហើយនិយាយទៅគឺមុខដូចតែគ្នាចឹងហាស
ហើយសំរាប់យើងដូចថាយើងបានរស់នៅជាមួយគ្នាចឹងទៅគឺយើងបានចូលនៅជាមួយនឹងគ្នាចឹងទៅហាសចាស
ហើយប្រសិនជាយើងបានទៅឆ្ងាយនឹងគឺយើងមិចនឹងដឹងហាសចាសហើយដល់ពេលចឹងគឺគេបានដើរជាមួយនឹងយើងចឹងទៅហាសចាសគឺគេបានបន្លំយើងចឹងទៅហាសចាស ៕
ក៖ បានិយាយទៅគឺគេបានបន្លំខ្លួននៅពេលដែលយើងមិនបានចាប់អារម្មណ៍មែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅនៅពេលដែលគេបានដើរចូលមកនឹងមាននាក់ខ្លះនឹងគឺគេបានបន្លំយើងចឹងទៅហាសចាសហើយមាននាក់ខ្លះនឹងគឺគេមិនបានស្គាល់នឹងក៏បានរស់រានមានជីវិតចឹងទៅហាស
ហើយសំរាប់នាក់ខ្លះនឹងគឺគេបានស្គាល់គាត់ចឹងទៅក៏បានសំលាប់គាត់ចោលតែម្តងចឹងទៅហាសចាស ៕
ក៖
បានហើយចឹងនៅក្នុងជំនាន់មុននឹងនៅពេលដែលគេបានយកមនុស្សនឹងទៅសំលាប់ចោលទាំងខ្សែៗនឹងថាតើសំរាប់លោកយាយដែលបានឃើញដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅសំរាប់ខ្ញុំនឹងគឺខ្ញុំមិនដែលបានឃើញនោះទេចាស
ក៏ប៉ុនតែនឹងនៅពេលដែលគេបានដឹកនឹងគឺខ្ញុំបានឃើញចឹងហាសចាស
គឺគេបានសំលាប់មនុស្សនឹងនៅខាងបកកងចឹងហាស
ហើយសំរាប់មួយនឹងនៅពេលដែលគេបានសំលាប់នឹងគឺគេបានអោយយចុះ
គឺគេបានអោយយើងនឹងបានឈរជាជួរចឹងទៅគឺគេបានបាញ់រះពេញនឹងហើយគេបានកហុសថាសំរាប់យើងទាំងអស់នឹងបានទៅទទួកសំម្តេចចឹងហាសចាស
ហើយសំរាប់ខ្ញុំបានឃើញផ្ទាល់ខ្លួនរបស់ខ្ញុំនឹងនៅចំកន្លែងអណ្តូលប្រេហាស
ហើយសំរាប់កន្លែងនឹងគឺមានកន្លែងចេញមួយចឹងហាសចាសហើយនិយាយទៅគឺខ្ញុំបានភ្លេចហើយដូចជាបានចេញមកពីគីឡូរលេខ៥ចាស់មកចឹងហាសចាស ហើយសំរាប់មួយនឹងគឺគេបានដឹកមកនឹងចឹងហាស
ហើយសំរាប់ស្រីម្នាក់នឹងគឺគាត់ស្អាតខ្លាំងណាស់ចាស
ហើយដូចថាគាត់នឹងបានពាក់របស់នឹងគឺជ្រើនចឹងហាសចាស
ហើយស្រីម្នាក់នឹងគឺគេមិននឹកស្មានចឹហាសនៅពេលដែលនិយាយជាមួយនឹងគេចឹងទៅគឺគេបានបាញ់គាត់នឹងសំលាប់ចោលតាមមាត់របស់គាត់ចឹងហាសចាស
ហើយនៅពេលដែលបាញ់តាមមាត់ហើយបានធ្លាយទៅក្រោយចឹងគឺស្រីម្នាក់នឹងបានដួលចុះហើយក៏បានបាញ់ស្រីម្នាក់នឹងថែមទៀតចឹងហាសចាស
ហើយយនៅពេលដែលគេបានសំលាប់ចោលហើយចឹងគឺគេបានយកមាសប្រាក់របស់គាត់ទាំងអស់នឹងយកមកហើយគេបានដេញយើងនឹងចេញស្រស់តែម្តងចឹងហាសចាសនឹងគឺប៉ុលនឹងឯងចឹងហាស
ហើយសំរាប់អ្វីផ្សេងទៀតនឹងគឺយើងមិនបានដឹងថាគេនឹងបានធ្វើអ្វីទៀតចឹងហាសចាស ៕
ក៖ បានហើយចឹងសំរាប់លោកយាយអត់បានដឹងថាគេបានធ្វើអ្វីខុសនោះទេមែនដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺគេមិនខុសនោះទេដូចថាម្នាក់នឹងគឺគេជាជំទាវចឹងហាស
ហើយនិយាយអោយស្រួលស្តាប់ទៅគឺគេជានាក់មានចឹងហាសចាស
ហើយសំរាប់មួយនឹងគឺមិនដឹងជាប្រពន្ធរបស់អស់លោកចឹងហាស
ហើយយើងមិនដឹងថាគេបានយកគាត់នឹងមកពីត្រឹមណាមកនោះទេចាស
ហើយសំរាប់មួយកូនមួយចៅនឹងគឺគេបានសំលាប់ចោលទាំងអស់ចឹងហាស
ហើយខ្ញុំបានឃើញហើយទាំងកូនហើយនឹងទាំងម្តាយនឹងគឺបានស្លាប់ទាំងអស់ចឹងហាសចាស ៕
ក៖
បានហើយចឹងនៅពេលដែលលោកយាយបានឃើញគេបានសំលាប់មនុស្សចឹងថាតើអារម្មណ៍របស់លោកយាយមានអារម្មណ៍យ៉ាងមិចដែលទៅលោកយាយ ???
ខ៖ ចាសនិយាយទៅសំរាប់អារម្មណ៍របស់ខ្ញុំនឹងគឺថាភ័យខ្លាំងណាស់ចាស
គឺថាភ័យចង់រាគអាចម៍នឹងបន្តិចហើយនឹងរាគនោមបន្តិចចឹងហាស
ពីព្រោះអីនឹងគឺយើងភ័យខ្លាំងណាស់ដែលចឹងហាសចាស
ហើយសំរាប់យើងនៅពេលដែលគេបានដេញយើងហើយចឹងគឺគេបានអោយអង្គរនឹងបានតែបន្តិចនោះទេ
ហើយសំរាប់អ្វីផ្សេងទៀតនឹងគឺថាយើងបានយកមកបានតែបន្តិចៗនោះទេសំរាប់ដាក់ជាមួយនឹងកងរបស់យើងនឹងហាសចាស
ហើយសំរាប់មានចាស់ៗនឹងដែលខ្ញុំបានឃើញនឹងគឺគាត់បានដើរកោងៗនឹងគឺខ្ញុំបានជួសទឹកនឹងហើយនឹងបានលាយអោយគាត់ទៀតនឹងហាសចាស ហើយសំរាប់យើងនឹងក៏បានរត់ទៅខាងអាងពារនឹងវិញចឹងហាស
ហើយចឹងក៏ស្ថានបានជំលៀសយើងនឹងទៅណាទៀតដែលចឹងហាសចាស ៕
ក៖
បានហើយចឹងសំរាប់អារម្មណ៍របស់លោកយាយនៅពេលដែលបានឃើញគេបានសំលាប់ចោលហើយចឹងលោកយាយមានអារម្មណ៍ភ័យមែនដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺយើងមានអារម្មណ៍នឹងថាតើភ័យខ្លាំងណាស់ចាស
ពីព្រោះអីនឹងនៅក្នុងជំនាន់នឹងគឺយើងដេកនឹងគឺមិនដែលបានលក់នោះទេ
ហើយសំរាប់ពេលខ្លះនឹងគឺគេបានយកមនុស្សនឹងពីក្រសារមួយនេះ
ហើយពេលខ្លះគឺយកក្រសារមួយនោះចឹងទៅហាសចាសនិយាយទៅគឺគេបានយកមនស្សនឹងនៅក្នុងសហរកណ៍នឹងចឹងហាស ហើយសំរាប់យប់ឡើងនឹងគឺខ្ញុំបានដេកនឹងបានទន្លេហើយចឹង
ហើយនឹងបុណ្យព្រះហើយសំរាប់ការជួយសង្គ្រោះជីវិតរបស់យើងនឹងចឹងហាសចាស
ហើយសំរាប់ព្រឹកនៅពេលដែលមានរងារនឹងក៏យើងនឹងបានបុណ្យព្រះរហូតចឹងហាសចាស
រហូតដល់ពេលព្រឹកនឹងបានភ្លឺនឹងបានច្បាស់ចឹងហាសចាស
ពីព្រោះអីនឹងនៅពេលដែលយប់ឡើងនឹងគឺគេដឹងតែយកមនុស្សនឹងទៅហើយសំរាប់មួយក្រសារៗនឹងចឹងហាសចាស និយាយទៅគឺគេបានយកមនុស្សនឹងទៅសំលាប់ចោលហើយចឹងហាស
ហើយសំរាប់កំហុសរបស់គេនឹងគឺគេមិនដឹងថាគេបានធ្វើអ្វីខុសចឹងហាសសំរាប់នៅជិតៗនឹងឯងគឺមិនបានទៅយកមនុស្សនឹងទៅពីចំងាយចឹងហាសចាស

ហើយសំរាប់ខុសអ្វីនឹងគឺយើងមិនបានដឹងនោះទេគឺយើងគ្រាន់តែបានដឹងថាគេយកមនុស្សនឹងទៅសំលាប់ចោលចឹងហាសចាស ។
ក៖
បាទហើយចឹងយើងគ្រាន់តែបានដឹងថាព្រឹកឡើងនឹងគឺគេបានយកមនុស្សនឹងទៅសំលាប់ចោលៗហើយមែនដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅនៅពេលដែលគេបានសំលាប់មនុស្សនឹងគឺមានតែពេលព្រឹក
ហើយនឹងពេលល្ងាចចឹងហាសចាស ហើយសំរាប់មួយព្រឹកជំចឹងហាស
ហើយសំរាប់មួយនឹងគឺដឹងតែគេបានយកទៅសំលាប់ចោលហើយចឹងហាសចាសនឹងសំរាប់កន្លែងរបស់ខ្ញុំដែលបានខ្ញុំបានរស់នៅចឹងហាសចាស
ហើយសំរាប់ការងារដែលយើងបានធ្វើអ្វីខុសអ្វីនឹងគឺយើងមិនបានដឹងនោះទេចាស
ហើយសំរាប់ជំនាន់នឹងគឺយើងបានដឹងថាយើងគ្រាន់តែអាចរស់នឹងបានដោយខ្លួនរបស់យើងនោះទេ
ហើយយើងមិនអាចយកមកនិយាយអោយគេបានដឹងអ្វីដែលយើងបានជួបនោះទេចាស
ហើយណាមួយនឹងក៏យើងមិនហ៊ានទឹងទៅសួរសុខទុក្ខនរណាម្នាក់ដែលចឹងហាសនៅពេលដែលយើងបានមកពីធ្វើការងារពលកម្មរបស់យើងនឹងហាសចាស
ហើយសំរាប់នាក់ណាមួយឆ្អែករឺក៏នាក់មិនបានហូបឆ្អែតនឹងគឺយើងគ្រាន់ដឹងថានៅពេលដែលយើងបានមករិញនឹងគឺយើងត្រូវតែមកសំរាកចឹងហាសចាស
ហើយសំរាប់យប់ឡើងនឹងនៅពេលដែលយើងដេកនឹងគឺយើងតែងតែបុណ្យរហូតចឹងហាសចាស
ហើយទំរាំតែកងទ័ពរបស់វៀតណាមនឹងគឺបានចូលមកជួយរំដោះនឹងគឺយើងមានរយៈពេលនឹងគឺយូរខ្លាំងណាស់ ហើយនៅពេលដែលបានមកជួយរំដោះហើយចឹងគឺខ្ញុំបានមករកទៅនៅខាងជុំរុំរិញចឹងទៅហាសចាស ។
ក៖ បាទហើយចឹងសំរាប់នៅក្នុងជំនាន់ប៉ុលពតនឹងថាតើគេមានសាសនាដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅនៅក្នុងជំនាន់នឹងគឺយើងគ្មានសាសនានោះទេចាស
ហហើយសំរាប់ផ្សារនឹងក៏គ្មានដែលចឹងហាស
ហើយសំរាប់យើងទាំងអស់គ្នាខំប្រឹងនឹងធ្វើការងារនឹងទាំងយប់ទាំងថ្ងៃនឹងនៅថែហូបមិនបានឆ្អែតទៀតចឹងហាសហើយប្រសិនជាអោយយើងនឹងបានហូបបានឆ្អែតវាមានទៅអ្វី ហើយសំរាប់សម្លៀកបំពាក់ក៏គ្មាន
ហើយសំរាប់អំបិលនឹងក៏គ្មានដែលចឹងហាសចាស
ហើយសូម្បីតែប្រហុកនឹងក៏គ្មានដែលចឹងហាសហើយសំរាប់ស្រុករបស់ខ្ញុំនឹងគឺនៅសល់តែកគោលឡែកនោះទេចាស ហើយសំរាប់ពេលខ្លះនឹងគឺគេបានដាក់ប្រហុកទៅហើយសំរាប់ពេលខ្លះនឹងគឺអត់មានប្រហុសនោះទេ
ហើយចឹងនៅពេលដែលយើងហូបទៅគឺធ្មេញរបស់យើងនឹងគឺខ្ចៅចឹងទៅហាសចាស
ហើយសំរាប់ការហូបចឹងទៅគឺយើងហូបទាំងយប់ទាំងថ្ងៃចឹងហាសធ្វើយ៉ាងមិចអោយតែយើងនឹងហូបចឹងហាសចាស ហើយនិយាយទៅធ្វើយ៉ាងមិចអោយតែយើងនឹងបានមួយរស់ចឹងហាស
ហើយសំរាប់បបរពេលខ្លះនឹងគឺគេបានយកដំឡងនឹងយកមកលាយចឹងហាសចាសនិយាយទៅសំរាប់ដំឡងនឹងនៅពេលដែលគេបានទៅចំការនឹងគឺគេបានយកដំឡងនឹងយកមកស្ងោរហើយនឹងបានកោសវាលាយជាមួយនឹងបបរហើយនឹងបាយរបស់យើងចឹងទៅហាស
ហើយសំរាប់មួយនឹងគឺវាមិនបានច្រើននោះទេតែវាគ្រាន់តែមិនបានដូចជានៅខាងតំបន់ ៥ នោះទេចាស
ហើយសំរាប់នៅខាងនេះវិញនឹងគឺគេបានហូបទាំងកន្ត្រកទៀតហាសចាស
និយាយទៅគឺគេបានយកកន្ត្រកនឹងយកមកអក ហើយនឹងលីងចឹងទៅ
ហើយសំរាប់ពេលខ្លះនឹងគឺគេបានយកមកដាក់ធ្វើជាន់ហើយនឹងធ្វើជាមួយនឹងស្លឹកក្តើលចឹងទៅហាសនៅក្នុងតំបន់មួយនេះចឹងហាសចាស
ហើយសំរាប់ក្រកូននឹងនៅពេលដែលយើងបានដើរមើលនឹងគឺយើងស្ងានតែជាដាមដើងរបស់មនុស្សចឹងហាស ហើយនៅពេលដែលយើងបានទៅមើលជិតវិញនឹងគឺជាលាមកឆ្កែទៅវិញចឹងហាសចាស
ពីព្រោះអីនឹងគឺយើងបានហូបមួយចឹងហាសចាស ហើយនិយាយទៅគឺយើងវេទនាខ្លាំងណាស់ណាចាស
ហើយសំរាប់ខ្ញុំគឺខ្ញុំមិនបានដល់ប៉ុននឹងនោះទេ គឺថាខ្ញុំបានហូបបានឆ្អែតចឹងហាស
ហើយគេបានអោយយើងនឹងបានហូបនឹងគឺមួយវែកៗចឹងហាស
ហើយសំរាប់ពលកម្មរបស់យើងនឹងគឺធ្វើទាំងយប់ទាំងថ្ងៃចឹងហាស
ហើយអត់មានសាសនានោះទេចាសនិយាយទៅគឺអត់ទាំងអស់តែម្តងនឹងហាស
ហើយសំរាប់រឿងរៀបការប្តីហើយនឹងប្រពន្ធនឹងគឺនៅពេលដែលគេរៀបការនឹងគឺគេបានចាប់អោយរៀបការនឹងចាប់ពី ៥០គូរ ទៅ ១០០ គូរហាសគឺបំពាក់គោជំហររបស់គេនឹងហាសចាស
ហើយគេបានអោយយើងនឹងបានដាក់ឡើងលើនឹងហើយនិយាយពាក្យផ្តាច់ផ្សារនឹងឯងគឺគ្មានអ្វីទៀតនោះទេចាស ។
ក៖
បាទហើយចឹងនៅពេលដែលអត់មានសាសនាចឹងនៅពេលដែលលោកយាយបាននិយាយធម៌ទាំងអស់នឹងថាតើលោកយាយបានចេះទាំងអស់នឹងបានមកពីណាដែលទៅលោកយាយ ???
ខ៖
ចាសនិយាយសំរាប់ខ្ញុំបានចេះពីដើមនឹងបានបន្តិចបន្តួចចឹងហាសចឹងហើយគឺខ្ញុំចេះតែទន្ទេញចឹងហាសចាស ពីព្រោះអីនឹងនៅពេលដែលខ្ញុំនៅតូចនឹងគឺខ្ញុំក៏ព្រោ ហើយចឹងគឺខ្ញុំចេះតែទន្ទេញចឹងទៅហាសចាស
ហើយសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគេបានដឹកខ្ញុំនឹងទៅបោះចោលនឹងនៅក្នុងព្រៃថេងនឹងហាសចាស
ហើយសំរាប់យប់ឡើងនឹងគឺស្ងាត់ខ្លាំងណាស់ ហើយសំរាប់ពេលព្រឹកនឹងក៏ចឹងដែលចឹងហាស
ហើយសំរាប់លោកយាយរបស់ខ្ញុំនឹងគាត់តែងតែប្រាប់ខ្ញុំនឹងអោយចេះសូត្រធម៌សំរាប់មានការជាំងបិទខ្ពួនរបស់យើងចឹងហាសចាស
ហើយដល់ពេលចឹងគឺខ្ញុំចេះតែចាំតាមអ្វីដែលលោកយាយរបស់ខ្ញុំនឹងគឺគាត់បានប្រាប់យើងចឹងទៅហាសចាស
ហើយនៅពេលដែលខ្ញុំបានចាំចឹងគឺខ្ញុំចេះតែប្រាប់កូនចៅរបស់ខ្ញុំនឹងតរហូតមកដល់កូនចៅរបស់ខ្ញុំចឹងទៅហាសចាស ។
ក៖ បាទហើយចឹងនៅក្នុងជំនាន់មុននឹងគឺយើងមានសាសនាដែលមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅសំរាប់នៅក្នុងជំនាន់សង្គមនឹងគឺយើងមានសាសនានឹងគឺក្រឹមត្រូវខ្លាំងណាស់ចាសហើយនឹងមានសាសនានឹងបានល្អខ្លាំងណាស់ ហើយសំរាប់ជំនាន់ លុន ណល នឹងគឺគេអាចពាក់ខ្លីបានចឹងហាស
ហើយសំរាប់ជំនាន់របស់សម្តេចតាគឺមិនអាចនឹងពាក់ខ្លីបាននោះទេចាសហើយសំរាប់ជំនាន់នឹងគឺសាសនានឹងគឺល្អខ្លាំងណាស់ចាសមិនមែនចេះតែនិយាយនោះទេចាស ។
ក៖
បាទហើយចឹងបាននិយាថាសំរាប់នៅក្នុងជំនាន់នឹងគឺយើងទាំងអស់គ្នានឹងគឺយើងមានសាសនាព្រះពុទ្ធដែល

មែនដែលរឺទេលោកយាយ
ហើយទើបតែមកដល់នៅក្តងដំនាន់ប៉ុលពតនឹងបានគេបានបិទដោលតែម្តងមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅនៅក្តងដំនាន់នឹងប្រសិនជាយើងមិនបានខុសអ្វីនឹងក៏គេបានយកយើងនឹងទៅវែចោលដែលចឹងហាសចាស ហើយសំរាប់ព្រះអង្គធំៗនឹងគឺគេបានវែហើយនឹងបោះចោលដែលចឹងហាសចាស
ហើយសំរាប់នៅខាងបឹងរាងនឹងគឺគេបានវែចោលអស់ហើយចឹងហាស
និយាយទៅគឺគេបានកំទេចអស់ហើយចឹងហាសចាសហើយនៅពេលដែលគេបានវែចោលនឹងគឺវែពេញនឹងហើយដាក់ពេញថ្នល់អោយយើងនឹងបានដើរលេងចឹងទៅហាសចាស
ហើយនិយាយទៅគឺគេមិនបានជឿយើងនោះទេ
ហើយនៅពេលដែលគេបានវែកន្លែងនឹងអស់ចឹងទៅគឺសំរាប់ពេលខ្លះនឹងគឺគេបានយកកន្លែងនឹងគឺយកដាក់គុកមនុស្សចឹងទៅហាសចាស ហើយនិយាយទៅគឺគេបានដាក់នៅក្តងកុមារកំព្រាចឹងទៅហាសចាស
ហើយនិយាយទៅគឺពួកប៉ុលពតនឹងគឺគេបានមកសំលាប់យើងហាស
ហើយនិយាយទៅគឺគេបានអោយយុវជនទៅវែយើងនឹងហើយប្រសិនជានាក់មិនទៅវែនោះទេគឺគេនឹងបាញ់យើងចោលនឹងហាសចាស
ហើយសំរាប់យើងដែលនៅពេលនឹងគឺយើងខ្លាចហើយដល់ពេលចឹងគឺយើងទៅវែតាមគេចឹងទៅហាសចាស
ហើយប្រសិនជាយើងមិនបានវែគេនឹងពួកប៉ុលពតនឹងវែយើងចោលចឹងហាសចាស
ហើយសំរាប់ពួកដែលវែនឹងគឺព្រះអង្គនឹងជំនួយណាស់ដែលពួកវានឹងបានវែហើយនឹងកំទេចចោលចឹងហាសចាស
ហើយដល់ពេលចឹងគឺអត់មានកន្លែងដែលស្ងាត់នោះទេចឹងហើយពួកវានឹងបានវែចោលតែម្តងចឹងហាសចាស ហើយសំរាប់កន្លែងនឹងគឺអត់មានស្អាយនោះទេហើយចឹងក៏បានធ្វើរឿងទាំងអស់នឹងចឹងហាសចាស
ហើយនិយាយទៅគឺសំរាប់ព្រះអង្គតូចហើយនឹងជំនឹងគឺគេបានវែចោលទាំងអស់ចឹងហាសចាស
ហើយនិយាយទៅគឺគេមិនបានទុក្ខនោះទេ ហើយពួកវានឹងមិនបានទុក្ខសាសនាអ្វីទាំងអស់ចឹងហាសចាស
ហើយសំរាប់ខ្ញុំបានភ្លេចចំរៀងរបស់គេហើយគឺមិនដឹងថាគេបានច្រៀងយ៉ាងមិចនោះទេចាសនិយយាទៅគឺខ្ញុំចាស់ហើយគឺខ្ចីមានអារម្មណ៍ភ្លេចអស់ច្រើនហើយចឹងហាសចាសហេហេហេហេ ៕
ក៖
បាទនិយយាទៅគឺយើងស្តាយថានៅក្តងដំនាន់នឹងគេបានប់បាក់អំពីសាសនាខ្មែររបស់យើងទាំងអស់នៅក្តងដំនាន់នឹងមែនទែនមែនដែររឺទេលោកយាយ
ពីព្រោះអីនឹងសំរាប់ខ្មែររបស់យើងនឹងគឺតែងតែមានជំនឿព្រះពុទ្ធសាសនារបស់ខ្មែរយើងមែនដែលរឺទេលោកយាយ???
ខ៖ ចាសៗ ៕
ក៖
បាទនិយាយទៅគឺថានៅពេលដែលគេបានរំលាយចឹងគឺដូចជាមានអារម្មណ៍ថាយ៉ាងមិចមិនដឹងនោះទេមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺខ្ញុំបានដេកសង្ឃឹមសំរាប់ស្រុករបស់យើងនឹងគឺនឹងមានថ្ងៃដែលគេបានចូលមកជួយប្រទេសរបស់យើងចឹងហាសចាសហើយក៏មិននៅចឹងជារៀងរហូតដែលចឹងហាសចាស
ហើយខ្ញុំបានប្រាប់កូនចៅរបស់ខ្ញុំនឹងចឹងហាស
ហើយសំរាប់ឪពុករបស់ខ្ញុំនឹងគឺគាត់មានគម្តីចឹងហាសគឺគាត់បានប្រាប់យើងថាសំរាប់សង្គ្រាមនឹងគឺនឹងជិតចប់ហើយ ហើយសំរាប់ដូងទុំហើយចឹងហាសចាស ហើយសំរាប់ដូងដែលបានជ្រុះហើយនឹងទុក្ខចោល
ហើយនឹងមានស្អីៗទៀតចឹងហាសដែលលោកគាត់បានបោះចោលដែលនៅក្តងដំនាន់រាស្ត្រនិយមនឹងហាសគឺយើងមិនដែលបានបោះចោលនោះទេចាសគឺយើងបានទុក្ខវារហូតចឹងហាស
គឺយើងមិនដែលបានបោះវាចោលនោះទេចាសហើយសំរាប់នៅក្តងដំនាន់នឹងគឺថាយើងបានរបស់ទាំងអស់នឹងហើយចឹងហាសចាសសំរាប់ការដាក់របស់របបយើងទៅណាមកណាចឹងហាសចាស
ហើយសំរាប់ខ្មែរក្រហមហើយនឹងវៀតណាមនឹងគឺពួកវានឹងបានម្នាក់នៅខាងលើហើយម្នាក់ទៀតនឹងនៅខាងក្រោមចឹងទៅហាស ហើយនៅពេលដែលបាញ់គ្នានឹងគឺគេចមិនផុតនោះទេ
ហើយសំរាប់ម្តាយរបស់ខ្ញុំហើយនឹងជីដូនរបស់ខ្ញុំនឹងគឺគាត់មេមាយជាង ៤០
ឆ្នាំទៅហើយចឹងហាសគឺគាត់បានប្រាប់រឿងទាំងអស់នឹងមកកាន់ខ្ញុំដែលចឹងហាសចាស
ហើយសំរាប់ខ្ញុំតែងតែប្រដៅកូនចៅរបស់ខ្ញុំនៅក្តងដំនាន់នឹងដែលចឹងហាសចាស
ហើយប្រសិនជាយើងមានសាសនា
ហើយនឹងផ្សារគឺល្អខ្លាំងណាស់ហើយសំរាប់វិន័យរបស់ពួកវានឹងគឺថាល្អម៉្យាងដែលចឹងហាសចាស
ហើយអត់មាននាក់ណាក្បត់នាក់ណានោះទេ
ហើយក៏គ្មាននាក់ណាហ៊ានទៅលួចរបស់នាក់ណាដែលចឹងហាសចាស
ហើយសំរាប់ការជិកក្បត់នឹងក៏គ្មានដែលចឹងហាស
ហើយនិយាយទៅគឺអោយតែពួកវានឹងបានអោយយើងនឹងស៊ីបានឆ្អែតចឹងហាសចាស
ហើយនឹងមានផ្សារអ្វីបន្តិចនឹងគឺវាល្អបាត់ទៅហើយចឹងសំរាប់យើងនៅក្តងដំនាន់នឹងចឹងហាសចាស
ហើយសំរាប់គ្នាបានធ្វើការងារនឹងគឺច្រើនខ្លាំងណាស់ដូចជាធ្វើបាន ៤០ ទៅ ៥០
គោនអីចឹងបានយើងនឹងបានហូបបានឆ្អែតចឹងហាសចាស
ហើយនៅពេលដែលយើងបានធ្វើបានហើយចឹងគឺយើងបានដឹកទៅអោយគេទាំងអស់ៗចឹងហាសចាស ៕
ក៖ បាទហើយចឹងសំរាប់ប្រជាជនគឺគេមិនបានហូបរបស់ទាំងអស់នឹងនោះទេ
ហយើគឺបានហូបតែបន្តិចបន្តួចតែប៉ុននឹងមែនដែលរឺទេលោកយាយ ???
ខ៖ ចាសហើយសំរាប់អង្ករមួយកំប៉ុងនឹងបានដាក់មួយខ្នះចឹងទៅ
ហើយសំរាប់ខាងរបស់ខ្ញុំនឹងគឺទាល់តែបានដាក់ ១០ កំប៉ុងអីនឹងបានគ្រាប់គ្នាចឹងហាស
ហើយសំរាប់នៅខាងនេះវិញនឹងគឺគេបានដាក់តែមួយកំប៉ុងតែប៉ុននឹងឯងចឹងអីហាស
ហើយប្រសិនជាមានចុងភៅដែលគេចិត្តអាក្រក់ទៀតចឹងគឺគេបានយកកន្ទោងប្រហុកនឹងយកមកដួសអោយយើងនឹងសំរាប់ហូបចឹងហាសចាស
ហើយនៅពេលដែលវាបានដួសហើយចឹងគឺពួកវានឹងបានយកមកដាក់ស៊ីតែខ្លួនរបស់វាចឹងទៅហាសចាស
ហើយសំរាប់យើងដែលអត់មាននឹងគឺយើងស៊ីលាយជាមួយនឹងត្រកួនអីចឹងទៅហាសចាស
ហើយនឹងបានចាប់ខ្យលចាប់ក្តាមចឹងទៅហើយនៅពេលដែលគេបានចាប់បានទៀតនឹងគឺគេនឹងសំលាប់យើងនឹងចោលទៀតចឹងទៅហាសចាស
ហើយចឹងបានថានៅខាងតំបន់របស់គេនឹងគឺមានភាពពិបាកខ្លាំងណាស់ប្រសិនជាគេចាប់ក្តាមបានហើយចឹងគឺគេបានឃើញចឹងគឺគេនឹងសំលាប់យើងចោលហើយចឹងហាស

តែសំរាប់ខាងរបស់ខ្ញុំនឹងគឺមិនពិបាកដល់ថ្នាក់ពេកនោះទេចាស
ហើយសំរាប់កន្លែងរបស់ខ្ញុំនឹងជួលកាល់នឹងគឺយើងមានប្រហុសសំរាប់ហូបចឹងទៅ
ហើយពេលខ្លះនឹងគឺយើងអត់មានសំរាប់ហូបចឹងទៅហាសចាសជួនកាល់នឹងគឺយើងមានត្រីមួយគឺគេបានធ្វើហូបទាំងអស់គ្នាចឹងទៅហាស ហើយសំរាប់ត្រូវមានបានស្គាល់ការទោលឡេកដែលរឺទេលោកគ្រូ ៕
ក៖ បាទហើយចឹងសំរាប់សត្វមួយនឹងគឺជាអ្វីដែលទៅលោកយាយ ???
ខ៖ ចាសនិយាយទៅសំរាប់មួយនឹងគឺជាបន្លែរបស់ចឹងហាសចាស
ហើយសំរាប់កន្ទោលឡេកនឹងគឺវាមានរាងស្រួចៗចឹងហាស ហើយវាមានរាងវែងចឹងហាស
ហើយនៅពេលដែលគេបានយកមកនឹងគឺគេបានហាន់វានឹងជាកង់ៗចឹងទៅហាសចាសហើយនៅពេលដែលដាក់ស្លរនឹងគឺទឹកវិញនឹងគឺខ្មៅខ្លាំងណាស់ ហើយធ្វើយ៉ាងមិចអោយតែយើងនឹងបានរស់ចឹងទៅហាសចាស ៕
ក៖ បាទនិយាយទៅសំរាប់នៅក្នុងដំនាន់នឹងអ្វីក៏យើងហូបទៅឆ្ងាញ់ដែលមែនដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅអ្វីក៏ឆ្ងាញ់ដែលចឹងហាសអោយតែបានសំរាប់យកមកហូបចឹងហាសចាស
ហើយសំរាប់ម្ហាក់នឹងអោយតែបានបាយនឹងគឺជីងតែឆ្ងាញ់ហើយចឹងហាស
ហើយនៅពេលដែលវៀតណាមគេបានចូលមកហើយបានអង្ករហើយនឹងស្បៀងចឹងហាសចាស
ហើយនៅពេលដែលបានបាយហើយចឹងគឺគេបាននិយាយថាអត់ឆ្ងាញ់នោះទេហើយទៅរកប៊ីចេងហើយនឹងប្រហុកហេហេហេហេ ៕
ក៖
បាទចឹងទៀតហើយនៅពេលដែលបានហើយគឺរបស់ទាំងអស់នឹងលេងឆ្ងាញ់ហើយសំរាប់ពួកគាត់មែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅនៅពេលដែលបានហើយចឹងគឺគេបានទៅរកស់ជាតិនឹងមានសាច់គោហើយនឹងសាច់ជ្រូកទៀតចឹងហាសចាស ៕
ក៖
បាទហើយចឹងសំរាប់លូវនឹងគឺបានសំបូរហើយនឹងសប្បាយនឹងគឺសាច់គោនឹងលេងឆ្ងាញ់ទៀតមែនដែលរឺទេលោកយាយ ???
ខ៖ ចាសនិយាយទៅគឺសំរាប់លូវនឹងទាំងអស់នឹងវាឆ្ងាញ់ហើយពីព្រោះអីនឹងគឺឆ្ងាញ់ចឹងហាសចាស
ហើយសំរាប់លូវនឹងគឺមានអ្វីទៀតពីព្រោះអីនឹងគឺយើងសុខសប្បាយទាំងអស់គ្នាហើយចឹងហាសចាស
ហើយនៅពេលដែលយើងទៅកន្លែងណានឹងក៏មានភាពសុខសប្បាយដែលចឹងហាសហើយទៅណាក៏មានភ្លើងទានដែលចឹងហាសចាស
ហើយណាមួយនឹងគឺយើងអរគុណសម្តេចហើយដែលគាត់បានដឹកនាំប្រទេសបានល្អចឹងហាសចាសហេហេហេ ៕
ក៖ បាទនិយាយទៅតាមពិតគាត់ពិតជាល្អខ្លាំងណាស់ក្នុងការដឹកនាំ
ហើយសំរាប់ខ្ញុំក៏ចូលចិត្តហើយនឹងជួយដល់ប្រជាជន
ហើយនៅពេលដែលបានលីហើយសំរាប់ខ្សែជីវិតរបស់ប្រជាជននៅក្នុងដំនាន់មុននឹងហើយគាត់បានជួយរំដោះប្រជាជនខ្មែរហើយសំរាប់គាត់ពិតជាល្អមែនចឹងហាសចាសហើយនឹងមិនអាចពិពណ៌នាបាននោះទេមែនដែលរឺទេលោកយាយ ???
ខ៖
ចាសនិយាយទៅគឺថាប្រសិនជាគ្មានសម្តេចនោះទេគឺគេបានសំលាប់យើងទាំងអស់នឹងគ្នានឹងចោលអស់ហើយចឹងហាសចាស
ហើយណាមួយនឹងគឺមានថ្ងៃមួយនឹងគឺគេបានណាត់យើងនឹងអោយបានហូបនុំបញ្ចុកហើយនឹងបង្អែមចឹងហាសចាស ហើយសំរាបទាំងអស់នឹងគឺជាតំរោងការការណ៍របស់គេចឹងហាស
ហើយសំរាប់មួយនឹងគឺគេបានរំដោះមុននឹងចឹងហាសចាស
ហើយប្រសិនជាចាំមុននឹងហើយយើងនឹងប្រកដជាអស់ហើយចឹងហាសចាសហើយកុំអីនឹងគឺគេបានសំលាប់យើងនឹងចោលអស់ហើយចឹងហាស
ចឹងហើយបានយើងនឹងបានអរគុណគាត់ខ្លាំងចឹងហាសចាសដែលគាត់បានជួយដល់ប្រជាជនហើយនឹងប្រជាពលរដ្ឋរាប់មឺុននាក់ចឹងហាសចាសហើយបានកើតកូនកើតចៅរហូតដល់ពេញទឹកពេញចឹងហាសចាស ៕
ក៖
បាទហើយចឹងសំរាប់ថ្ងៃនឹងអរគុណច្រើនមែនទែនលោកយាយដែលបានចែកចាយពីបទពិសោធរបស់លោកយាយច្រើនហើយក៏សង្ឃឹមថាក្មេងៗជំនាន់ក្រោយនឹងអោយគាត់នឹងមានភាពតស៊ូហើយក៏ដូចជាចាស់ៗនៅក្នុងដំនាន់មុនចឹងហាស
ហើយជាពិសេសនឹងអោយគាត់នឹងធ្វើជាកូនល្អហើយនឹងពលរដ្ឋហើយនឹងគេចផុតពីគ្រឿងញៀនហើយនឹងធ្វើចៅល្អសំរាប់ឪពុកម្តាយផងដែល ???
ខ៖
ចាសនិយាយទៅប្រសិនជាកូនៗដែលមានម៉ូតូហើយនឹងគឺសូមអោយបើកបរម៉ូតូនឹងអោយបើកបរនឹងអោយតិចៗចឹងហាស
ហើយសំរាប់ខ្ញុំមានកូនម្ហាក់នឹងហើយគ្រោះថ្នាក់ចរាចរណ៍នឹងហើយមិនបាននិយាយជាមួយម្តាយបានមួយមាត់នោះទេគឺទៅតែងស្លងទាំងអស់ចឹងហាស ហើយសំរាប់ពេលនឹងគឺជាថ្ងៃបិណ្ឌមួយចឹងហាស
ហើយមិនបានអ្វីមកវិញនោះទេគឺអស់ម៉ូតូទៀត
ហើយសំរាប់ម៉ូតូនឹងគឺយើងបានបង់រំលួសទៀតហើយយើងមិនទាន់បានសង់គេអស់ផងនឹងហាសរហូតមកសព្វថ្ងៃនឹងហាសចាស ហើយសំរាប់វានឹងបានកំព្រាចៅមួយនឹងធ្លាក់មកលើយាយទៀតចឹងហាសចាស
ហើយនិយាយទៅគឺវាបានបាត់ខ្លួនចឹងហាស
ហើយនៅពេលដែលយើងដើររកនឹងទៅវត្តនឹងក៏មិនបានឃើញហើយទៅណានឹងក៏យើងមិនបានឃើញដែលចឹងហាសចាស ហើយនិយាយទៅគឺយើងរកមិនបានឃើញតែម្តងនឹងហាសចាស
ហើយនិយាយទៅគឺបាត់កូនស្រី ១ ហើយនឹងកូនប្រុស ១ ចឹងហាសហើយសំរាប់នាក់ដែលមានផ្ទៃពោះក៏ដោយសូមអោយកូនទាំងអស់នឹងទៅពេទ្យហើយនឹងពិនិត្យសុខភាពហើយប្រសិនជាមានរឿងអ្វីនឹងសូមអោយទៅពីគ្រោះជាមួយនឹងពេទ្យចឹងហាសចាសហើយកុំអោយដូចជាកូនរបស់ខ្ញុំចឹងហាសហើយប៉ុននឹងបានហើយសូមអរគុណ ៕
ក៖
បាទហើយចឹងអរគុណច្រើនមែនទែនហើយសូមជូនពរលោកយាយអោយមានសុខភាពល្អហើយនឹងកំលាំងនឹងមាំមួនហើយនឹងអរគុណច្រើនសំរាប់ពេលវេលាដ៏មានតំលៃរបស់លោកយាយដែលបានចែកចាយពីបទពិសោធន៍របស់លោកយាយទៅកាន់មនុស្សទូទៅអោយគាត់បានស្គាល់ពីខ្សែជីវិតរបស់លោកយាយ

ហើយនឹងមានការព្រមព្រៀងប្រយ័ត្នអ្វីដែលត្រូវធ្វើចឹងហាសបានហើយចឹងប្រហែលជាខ្ញុំបញ្ចប់ជាមួយនឹងលោកយាយផងដែលហើយចឹងអរគុណច្រើនហើយជំរាបលាណាលោកយាយសូមអោយសុខសប្បាយណាលោកយាយ ???
ខ៖ ចាសនិយាយទៅសូមអោយលោកគ្រូទៅណាមកណានឹងអោយសុខសប្បាយ
ហើយនឹងសុខសប្បាយដូចអ្វីដែលយាយបាននិយាយចឹងហាសចាសហើយកុំអោយជួបអ្វីដែលអាក្រក់ចឹងហាសចាស ។
ក៖ បានហើយចឹងអរគុណច្រើនហើយចឹងជំរាបលាលោកយាយ ។